សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធានា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

## ព័ត៌មានសំខាន់ៗខាងក្នុង...

ឆ្នោត DV មករស់នៅអាមេរិកចាប់ផ្តើមទទួលការចុះឈ្មោះហើយ...

សូមអាននៅទំព័រទី ១៥




ថវិការជំនួយចំនួន១លានដុល្លាររបស់ប្រសួង ការងារសម្រាប់ម្រោងការអភិវឌ្ឍន៏ធនធាន យុវជនឡូវែលរបស់អង្គការខំញ្ញូនីធី ធីមវឺក

**Community Teamwork Announces YouthBuild of Greater Lowell Receives Department of Labor Funding**

សូមអាននៅទំព័រទី ០៥




ពីរសប្តាហ៏សម្រាប់ជួបក្រុមគ្រួសារនៅប្រទេសបារាំង...

សូមអាននៅទំព័រទី ១៣



# វរជននយោបាយ៣នាក់បានមកកាន់ឡូវែល

**ខ្មែរផុសស.រ.អា**

ប្រជាពលរដ្ឋខ្មែរនៅឡូវែលមានសំណាងច្រើន ដោយក្នុងខែសីហានេះ មានវរៈជននយោបាយខ្មែរ៣រូបបានមកដល់ទីក្រុងដ៏សម្បូរខ្មែររស់នៅ នាជ្រោយខាងកើតនៃសហរដ្ឋអាមេរិក - លោកទាំងនោះមាននាមៈ លោក ហុង លីម ជាតំណាងរាស្ត្រខ្មែរ-អូស្ត្រាលីនៅរដ្ឋវិកតូរីយ៉ា ជាអ្នកការពារប្រជាពលរដ្ឋខ្មែរយ៉ាងប្តូរផ្តាច់ពីរដ្ឋសភាប្រទេសអូស្ត្រាលី - លោក យឹម សុវណ្ណ ជាតំណាងរាស្ត្រខ្មែរនឹងជាអ្នកនាំពាក្យខាងគណបក្សសង្គ្រោះជាតិ -ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ ជាសមាជិកគណកម្មការនាយកនឹងជាបេក្ខជនសភាជាតិរបស់គណបក្សសង្គ្រោះជាតិទាំង៣រូបសុទ្ធតែជាអ្នកតស៊ូប្រឆាំងនឹងអំណាចផ្តាច់ការរបស់លោកនាយករដ្ឋមន្រ្តីខ្មែរ ហ៊ុន សែន ដែលកំពុងតែមានសកម្មភាពកំចាត់គណបក្សប្រឆាំង តាមក្រៅប្រព័ន្ធច្បាប់នឹងរដ្ឋធម្មនុញ្ញខ្មែរ។ អ្នកនយោបាយទាំង៣រូប សុទ្ធតែធ្លាប់មានប្រជាប្រិយភាពខ្ពស់ស្រឡាញ់សេរីភាពនឹងយុត្តធម៌, បានមកធ្វើការពន្យល់ដល់សហគមន៏ឡូវែលអំពីព្រឹត្តិការណ៏នយោបាយធ្ងន់ធ្ងរនៅកម្ពុជា ជូនប្រជាពលរដ្ឋដែលធ្លាប់តែមានសុឆន្ទៈចំពោះប្រទេសជាតិខ្លួនមិនដែលឈប់, បើអ្នករស់នៅខាងក្រៅមិនជួយកម្ពុជាទេ ប្រទេសនោះនឹងត្រូវលោក ហ៊ុន សែន នាំយកទៅលក់ឱ្យកុម្មុយនីស្ត រួចប្រើញយកជាសម្បត្តិផ្ទាល់គ្រួសារខ្លួនជាមិនខាន។ អ្នកស្រុកឡូវែល ក៏បានទទួលស្វាគមន៏វរជនទាំង៣រូបនោះ យ៉ាងកក់ក្តៅវិញដែរ ៕


លោក ហុង លីម


ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ


លោក យឹម សុវណ្ណ

សូមអានអត្ថបទនៅទំព័រទី១០
សូមអានអត្ថបទនៅទំព័រទី១៦

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៏
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

ឱកាសបណ្តុះបណ្តាលផ្នែកផលិតកម្មជាន់ខ្ពស់ បើកចុះឈ្មោះដោយឥតគិតថ្លៃនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលមុខរបរឡូវែល

## Advance Manufacturing Training Opportunity

is Open for Free Enrollment at the Lowell Career Center

Please Read Page 07



## បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

### អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$320** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
License # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

# ឡូវែលសម្ពោធរូបសំណាកខ្មែរតាំងនៅមុខសាលាក្រុង

**តពីលេខមុន**

**ខ្មែរផុសស.រ.អា.**

រូបសំណាកសម្ពោធ"ខ្មែរភៀសខ្លួន"ដំណាងឱ្យប្រជាពលរដ្ឋខ្មែរ ដែលបានមករស់នៅជាភូមិកំណើតទី២ នាទីក្រុងឡូវែល បានត្រូវដំឡើងនឹងសម្ពោធយ៉ាងឱឡារិក នៅមុខសាលាក្រុងកាលពីថ្ងៃអាទិត្យ ទី២៤ កញ្ញា២០១៧ កន្លងទៅ ក្រោមការដឹកនាំដ៏ខ្នះខ្នែងរបស់លោក រ៉តនី អេលីយ៉ុត អតីតអភិបាលក្រុង បច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាក្រុងឡូវែលនឹងស្ថាបនាដោយវិចិត្រករ យ៉ារី លីវ៉ាន ជាអតីតសិល្បករមហាវិទ្យាល័យវិចិត្រសិល្បៈជំនាញចំនួនតិតួចសល់ពីវាលពិឃាតខ្មែរក្រហម ។

គណកម្មការពិគ្រោះយោបល់មានគ្នាប្រមាណ ៣០នាក់ មកពីគ្រប់មជ្ឈដ្ឋាននឹងមានគណកម្មការអចិន្ត្រៃយ៍មាន៦នាក់ ដែលជួយលោក រ៉តនី អេលីយ៉ុត រហូតដល់បានសម្រេចលទ្ធផលបានប្រសើរដែលជាអាទិ៍មានៈ

ស៊ូសី អិន, វណ្ណា ហូវីដ, សារ៉ា ខេង-ឡេង, ម៉ូលីកា តាំង, សុខផល ប៉ែន, នឹងមនុស្សម្នាក់ទៀតដែលប្រឹងធ្វើការដើម្បីរូបសំណាក់នេះដែរ តែបានរងគ្រោះថ្នាក់លិចទូកដល់ស្លាប់កាលពីខែមិថុនា គឺ ឈឿន ឈុន...

They are: Susie-In, Vanna Howard, SaraKhen-leng, MolykaTaing, Sok Paul Pen. The other person that worked so hard, was ChhoeunChhun, who died tragically in the boating accident in June ។

ចំណាយមានគ្រោង៤ម៉ឺនដុល្លាដែលមានអ្នកចូលរួមថវិការធំៗមាន

Attached is the lost of sponsors from $5000 to $300

Lowell five cents Savings Bank$5,000 – Glory Buddist Temple $5,000 – Nancy Donahue Foundation $2,500 – Lowell General Hospital $2,500 – Wheelabrator Technologies $2,500 – Khmer Post USA $1,000 – Jeanne d'Arc Credit Union $1,000 – Entreprise Bank $1,000 – Vanna & Greg Howard $1,000 – Paul RathaYem $ 1,000 – Trinity EMS $1,000 Hong Kong Market $500 – Bayon Market $500 – Ten Men Inc. $500 – Ramos Package Store $500 – Woodard & Curran $500 – Madison Security $500 – Seng a Eg $500 – Lowell Aestthetic& Nail Academy $500 – Jeanne & Alan Lightman $500 – Gallagher &Cavanaugh LLC $500 – Attorney Louis Haskell $500 – Cambodian Mutual assistance Association 4៣00 – Kazanjian Entreprise $300 – KK Insurance $300 – Middlesex Physical Therapy $300 – One World Phamacy $300 – United Health Care $300 – Citizens Bank $300

There are many,many more sponsor from $250 to $50.


លោក រ័ត្ននី អ៊ីលីយ៉ុត និងក្រុមអ្នកជំនួយការរកថវិកាធ្វើរូបសំណាកជនភៀសខ្លួន


លោក យ៉ារី លីវ៉ាន់ និងភរិយា

រូបសំណាកជនភៀសខ្លួនខ្មែរដែលមួយផ្ទាំងឈរមួយកំពស់មនុស្សក្រាលដោយឥដ្ឋពណ៌ក្រហមមានឆ្លាក់ឈ្មោះសប្បុរសជនជាអមតៈលើនោះ, ឥឡូវនេះបានក្លាយជាតំណាងឱ្យប្រជាពលរដ្ឋដែលមានប្រវត្តិជូរចត់កាលពីនៅប្រទេសដើមរបស់ខ្លួន, ធ្វើឱ្យរក្សាការចងចាំពីប្រវត្តិរបស់ខ្លួន ទុកជូនកូនចៅជំនាន់ក្រោយឱ្យដឹងថា "តើពូជសាសន៏ខ្លួនដែលរស់នៅតំបន់ឡូវែលនេះ មកពីណា?" រូបចម្លាក់នេះ បានទទួលការសរសើរច្រើនជាងការរិះគន់ដោយទទួលបានការបោះឆ្នោតយល់ព្រមពីប្រជាពលរដ្ឋខ្មែរនៅឡូវែលនេះ ហើយក៏មានការប្រកួតប្រជែងជាមួយសិល្បៈករចម្លាក់ពីររូបទៀត កាលពី២ឆ្នាំមុននៅវត្តពន្លឺពុទ្ធចក្រ ។

នៅជិតគ្នានេះដែរ ក៏មានរូបសំណាកសាសន៏ផ្សេងៗទៀត ដូចជាសាសន៏"អាកមេនី" ជាដើមដែលធ្លាប់បានរងគ្រោះដោយសាររបបប្រល័យពូជសាសន៏"ហ៊ីត្លែ"នៃប្រទេស អាល្លឺម៉ង់ ក៏មាននៅទីនោះ តាំងពីមុនមកដែរ ៕



# លទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាក្រុងឡូវែល

**ដោយ ពិន សំខុន** : លទ្ធផលនៃការបោះឆ្នោតថ្ងៃទី២៦កក្កដា២០១៧ បានបង្ហាញថា: សង្កាត់"បែលវីខ្បៀ"នៅតែមានឥទ្ធិពលលើសេចក្តីសម្រេចក្រុងឡូវែលទាំងមូលដូចសព្វមួយដង គឺក្រុមដែលកាពារវិទ្យាល័យនៅ"ដោនថោន" បានឡើងខ្ពស់ទាំងអស់ - សម្លេងរបស់ វ៉ាស្នា នួន ដែលពីមុនចាញ់ដោយសារគ្មានឆ្នោត "បែលវីខ្បៀ" ឥឡូវកើតចំនួនដោយសារបែលវីខ្បៀអាចនឹងត្រូវការបេក្ខជន"ភាគតិច"ម្នាក់ឱ្យនៅក្នុងចំណោមអ្នកឈ្នះ ដើម្បីនឹងទប់ទល់កាចោទប្រកាន់ពីករណីបណ្តឹងទៅតុលាការស្តីអំពី "ភាពអយុត្តិធម៌ផ្ទុយពីស្មារតីនៃរដ្ឋធម្មនុញ្ញ"។ ក្រុមអ្នកគាំទ្រ "ខលី" មានការខកចិត្តច្រើន ដោយក្រុមមានឥទ្ធិពលខាង "ដោនថោន" ចាញ់សេចក្តីសម្រេចស្របច្បាប់ហើយ នៅតែ"ឡាំប៉ា" បន្តធ្វើសកម្មភាពមិនព្រមចាញ់ដដែល។

មានឆ្នោតខ្ពស់របស់អ្នកគាំទ្រ"ដោនថោន", ហើយអ្នកដែលធ្លាប់ខ្ពស់ពីមុនៗមកបែរជាធ្លាក់ចុះទាប ដូចជា រ័តនីយ អេលីយ៉ុត ឬ រីដា មឺស្សៀជាដើម, តែនេះក៏មិនមែនបានន័យថា ខាង "ខលី"អស់ផ្លូវត្រូវតែចាញ់នោះនៅឡើយទេ ។ យកឈ្នះអ្នកបានសន្លឹកឆ្នោតជាងពាពាន់មិនជាការលំបាកប៉ុន្មានទេ! ឱ្យតែ"ហាយឡិន - ប៉ាតាក់វិល..."ពួតដៃគ្នាទទួលខុសត្រូវលើវាសនាកូនចៅខ្លួន ហើយចេញទៅបោះឆ្នោតនោះមុខជានឹងឈ្នះជាមិនខាង ។ ឈ្នះពេលនោះ គឺឈ្នះពីរដងដោយ ១-កុំជ្រើសយកវិទ្យាល័យក្នុងអាគារចាស់នៅ"ដោនថោន"គឺឈ្នះបានវិទ្យាល័យថ្មីស្រឡាងនឹងធំទូលាយសម្រាប់កូនចៅ ២-កុំបោះឆ្នោតឱ្យក្រុមឡាំប៉ា ដែលមិនគោរពដំណើរការច្បាប់ ហើយនឹងឈ្នះបានក្រុមអ្នកដែលចេះគោរពឆន្ទៈបានចែងក្នុងច្បាប់ពីមុនមកហើយផង៕

CITY COUNCIL

| | Total | |
|---|---|---|
| Number of Precincts | 33 | |
| Precincts Reporting | 33 | 100.0 % |
| Times Counted | 7680/65490 | 11.7 % |
| Total Votes | 51071 | |
| Times Blank Voted | 45 | |
| Times Over Voted | 134 | |
| EDWARD J KENNEDY, JR | 3266 | 6.40% |
| JOHN J LEAHY | 3262 | 6.39% |
| WILLIAM BILL SAMARAS | 3254 | 6.37% |
| VESNA NUON | 3095 | 6.06% |
| RITA M MERCIER | 3073 | 6.02% |
| JAMES L MILINAZZO | 3057 | 5.99% |
| DAVID J CONWAY | 2834 | 5.55% |
| RODNEY M ELLIOTT | 2700 | 5.29% |
| DANIEL P ROURKE | 2479 | 4.85% |
| JAMES JIM LEARY | 2466 | 4.83% |
| COREY A BELANGER | 2262 | 4.43% |
| KAREN A CIRILLO | 2224 | 4.35% |
| MATTHEW E LeLACHEUR | 2150 | 4.21% |
| DANIEL M FINN | 2140 | 4.19% |
| SOKHARY CHAU | 2115 | 4.14% |
| MARTIN J HOGAN | 1822 | 3.57% |
| JOSEPH P BOYLE | 1758 | 3.44% |
| ROBERT GIGNAC | 1746 | 3.42% |
| PAUL RATHA YEM | 1638 | 3.21% |
| JOSE W NEGRON | 1536 | 3.01% |
| PAN SO | 1025 | 2.01% |
| JEFFREY S WILSON | 636 | 1.25% |
| ROBERT W MERRILL, JR | 493 | 0.97% |
| Write-in Votes | 40 | 0.08% |

ព័ត៌មានខ្លីៗ

## បន្ទាប់ពី"ម៉ារីយ៉ា"ឥឡូវខ្យល់ព្យុះ "ណេត"នឹងមកដល់ទៀត

**ព័រតូរីកូៈ** ខ្យល់ព្យុះ "ម៉ារីយ៉ា" ទើបនឹងបញ្ចប់បោកបក់បំផ្លាញ"ព័រតូរីកូ" ដែលជាកោះរបស់អាមេរិកនាំឱ្យមានការខូចខាតមានកំរិតធ្ងន់ធ្ងរលោកប្រធានាធិបតី ឌុណល ត្រម បានទៅធ្វើទស្សនកិច្ច នាទីក្រុងមួយតូចមួយនេះដោយចុះយន្តហោះនៅទីនោះចំនួន៤ម៉ោង បានជួបប្រាស្រ័យជាមួយអភិបាលក្រុង រីកាដូ រ៉សែឡូ ដែលជាអ្នកនាំផ្លូវលោកប្រធានាធិបតីឱ្យបានឃើញកន្លែងខូចខាតសំខាន់ៗ ដែលស្ទើរតែគ្មានសល់។

ប្រជាពលរដ្ឋនៅខ្វះអគ្គិសនីប្រើប្រាស់(៩0%) នៅឡើយទេ ខ្វះទឹកស្អាតនឹងគ្មានប្រេងចាក់រថយន្តនៅឡើយដែរ សាលារៀនមិនទាន់ដំណើរការបានដោយខ្វះអគ្គីសនី -មនុស្សជាច្រើនបានចាកចេញពី"ព័រតូរីកូ"មករកជម្រកនៅរដ្ឋ"ហ្លរីដា" ដែលអភិបាលក្រុងបានពិពណ៌នាថា "មានប្រជាពលរដ្ឋ"ព័រតូរីកាន"១0,000នាក់ហើយ បានមកដល់រដ្ឋហ្លរីដា។

មកដល់សេដ្ឋវិមានវិញ លោក ដណល ត្រម បានស្នើថវិការ២៩ប៊ីលីយ៉ន សម្រាប់ជួយស្រោចស្រង់ ព័រតីរីកូ ឱ្យបានត្រឡប់មានជីវភាពធម្មតាវិញ។

មិនទាន់ស្ងប់ខ្យល់ផង តំណឹងខ្យល់ព្យុះដ៏ខ្លាំងមួយទៀតក៏មកដល់ គឺខ្យល់ព្យុះ"ណេត" ដែលនឹងមកដល់ដីគោក នៅថ្ងៃសៅរ៍ខាងមុខ ដែលគេទាយថានឹងបោកបក់ប៉ះរដ្ឋ អាឡាបាម៉ា រដ្ឋល្វីស្យាណា នឹងរដ្ឋហ្លរីដា ក្នុងល្បឿន៩0ម៉ាយក្នុង១ម៉ោង៕



# ថវិការជំនួយចំនួន១លានដុល្លាររបស់ក្រសួងការងារសម្រាប់គម្រោងការអភិវឌ្ឍន៍ធនធានយុវជនឡូវែលរបស់អង្គការខំញ៉ូនីធី ធីមវ៉ឹក

**ដោយ សុខារ័ត្ន កូយ**

ឡូវែល-កាលពីពេលថ្មីៗនេះ អង្គការខំញ៉ូនីធី ធីមវ៉ឹក (Community Teamwork) បានទទួលថវិការជាជំនួយដែលមានចំនួនទឹកប្រាក់ ១ លានដុល្លារ ពីក្រសួងការងារសហរដ្ឋអាមេរិក ដើម្បីអនុវត្តគម្រោងមួយដែលមានឈ្មោះថា ការអភិវឌ្ឍន៍ធនធានយុវជនឡូវែល (YouthBuild of Greater Lowell) រយៈពេល៣ឆ្នាំ។ គោលបំណងនៃគម្រោងនេះ គឺដើម្បីជួយយុវជនឱ្យ




បញ្ចប់ការសិក្សា និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅដោយខ្លួនឯង។

បើតាមព័ត៌មានរបស់អង្គការខំញ៉ូនីធី ធីមវ៉ឹគ ចេញផ្សាយកាលពីថ្ងៃទី៣០ ខែសីហា បានឱ្យដឹងថា ជំនួយនេះនឹងជួយដល់យុវជនដែលកំពុងជួបហានិភ័យចំនួន១៣០នាក់ តាមរយៈគម្រោងការអភិវឌ្ឍន៍ធនធានយុវជនឡូវែលឱ្យមានឱកាសចូលរួមក្នុងកម្មវិធីអប់រំដ៏ទៃផ្សេងទៀតនៅក្រុងឡូវែល ខណៈពេលដែលកំពុងមានជំនាញការងារសំខាន់ៗរួចទៅហើយ។

ប្រភពដដែរបានបន្តថា គម្រោងអភិវឌ្ឍន៍ធនធានយុវជននេះ នឹងផ្តោតទៅលើធាតុផ្សំសំខាន់ៗមួយចំនួនដូចជាការអភិវឌ្ឍន៍ភាពជាអ្នកដឹងនាំ និងការបំរើសេវាសហគមន៏។ ជាមួយគ្នានេះផងដែរ គម្រោងនេះ ក៏ផ្តល់នូវការបង្រៀន និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលអាចឱ្យយុវជនចូលសិក្សានៅវិទ្យាល័យ ឬទទួលបានវិញ្ញាបនបត្រដែលទទួលស្គាល់ដោយរដ្ឋផ្សេងទៀត និងវិញ្ញាបនបត្រដែលទទួលស្គាល់ទាក់ទងនឹងវិស័យឧស្សាហកម្ម ដូចជាសំណង់ និងវិស័យផ្សេងទៀត។

គម្រោងនេះនឹងធ្វើអនុវត្តន៏ចំពោះយុវជនដែលមានអាយុចាប់ពី១៦ឆ្នាំ ទៅដល់២៤ឆ្នាំ ដែលស្ថិតក្នុងប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជន, ផុតអាយុពីការចិញ្ចឹមរបស់ឪពុកម្តាយ, បោះបង់ការសិក្សានៅវិទ្យាល័យឬកំពុងទទួលរងហានិភ័យមិនអាចឈានដល់គោលដៅអប់រំនិងការងាររបស់ខ្លួន។

លោក ខារេន ហ្វ៊ីដ៍រីក នាយកប្រតិបត្តិអង្គការខំញ៉ូនីធី ធីមវ៉ឹក បានមានប្រសាសន៏ថា "យើងរីករាយដែលយើងមានសក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាននូវជំនួយថវិការពីក្រសួងការងារដោយផ្អែកទៅលើគុណភាពនៃការរៀបចំកម្មវិធីរបស់យើង និងតំរូវការនៅក្នុងសហគមន៏របស់យើង"។

លោកបន្តថា "ជំនួយថវិការនេះ នឹងផ្តល់ឱកាសជាច្រើនដល់យុវជនជាច្រើនដើម្បីទទួលបានជោគជ័យ, ស្វែងយល់ពីខ្លួនឯងជាថ្មី និងធានានូវការងារដែលមាននិរន្តរភាព ឬជោគជ័យ ចំពោះការអប់រំនាពេលអនាគត"។

ចំណែកលោក ចន ខាវ ប្រធានគម្រោងការអភិវឌ្ឍន៏ធនធានយុវជនឡូវែលបានបញ្ជាក់ថា "យើងត្រេកអរ និងសប្បាយរីករាយទទួលបាននូវជំនួយថវិការនេះពីរដ្ឋាភិបាលសហព័ន្ធ។ ថវិការនេះនឹងពង្រឹងការងារបុគ្គលិករបស់រយើង ដោយអនុញ្ញាតឱ្យយើងជួលនូវជួលគ្រូបណ្តុះបណ្តាលផ្នែកសំណងផ្សេងទៀត, អ្នកគ្រប់គ្រងការងារសំណង ព្រមទាំងគ្រូបបង្រៀន HiSET ពេញម៉ោងផងដែរ។ ជាងនេះទៅទៀត យើងនឹងអាចផ្តល់ការបង្រៀនបន្ថែម និងការគាំទ្រដែលចាំបាច់ផ្សេងទៀតសម្រាប់សិស្សរបស់យើង"។

ចំពោះលោកស្រីសមាជិសភា នីគី សាន់ហ្គាស បានសម្តែងការរីករាយ និងអបអរសាទរចំពោះអង្គការខំញ៉ូនីធី ធីមវ៉ឹក ដែលបានទទួលទឹកប្រាក់ចំនួន១លានដុល្លារពីក្រសួងការងារសម្រាប់គម្រោងអភិវឌ្ឍន៏ធនធានយុវជនដែលអាចជួយលើកកំពស់ជំនាញការងារ និងការអប់រំរបស់យុវជនខាងផ្នែកសំណង និងផលិតកម្ម។

គួរបញ្ជាក់ថា អង្គការ ខំញ៉ូនីធី ធីមវ៉ឹក គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញដែលមានគោលបំណងធ្វើការផ្លាស់ប្តូរសង្គមតាមរយៈការជួយមនុស្សឱ្យចេះជួយខ្លួនឯង តាមរយៈជំនួយពីគ្រួសារ, អាហារូបត្ថម្ភ, ការស្នាក់នៅ, ការបណ្តុះបណ្តាលជំនាញ, ការផ្តល់ការងារ, ហិរញ្ញវត្ថុក្នុងការសិក្សា និងការអភិវឌ្ឍន៍អាជីវកម្មខ្នាតតូច។ បច្ចុប្បន្ននេះ អង្គការនេះ បានជួយយុវជនប្រហែល ៥0,000 នាក់មកពីក្រុងចំនួន៦៣ នៅភាគឥសាន្តនៃរដ្ឋម៉ាសាឈូសេតឱ្យមានឯករាជខាងផ្នែកសេដ្ឋកិច្ចប្រសើរជាងមុន៕

# Community Teamwork Announces YouthBuild of Greater Lowell Receives Department of Labor Funding

Lowell, MA-More than 130 at-risk youth will have the opportunity to participate in alternative edu cation programs in Lowell while mastering critical job skills thanks to a $1.1 million grant from the US Department of Labor made to Community Teamwork's Youth Build of Greater Lowell program to cover a 3-year term.

YouthBuild provides classes that lead to a high school or other state-recognized diploma and industry-recognized certifications in construction and other fields. Leadership development and community service also are key components of YouthBuild. The goal is to help young people complete their education and achieve economic self-sufficiency. It is a community-based alternative education program that provides classroom instruction and occupational skills training to youth ages 16 to 24 who have been in the juvenile justice system, are aging out of foster care, have dropped out of high school, or are otherwise at risk of failing to reach educational and career milestones.

John Cave, Director of Youth Build of Greater Lowell exclaimed, "We are ecstatic and pleased to receive this resource from the Federal Government. This grant will enhance our staffing, allowing us to hire another construction trainer and case manager, as well as a part-time HiSET instructor. It will also extend our current HiSET Instructor's hours to a full time position. We will now beable to provide extended tutoring and other needed supports for our students."

One way this DOL grant augments CTI/YouthBuild programming is that it allows them to be recognized as a Construction -Plus program. A second direct career track will also be expanded. The pilot Culinary Arts program will provide new opportunities for students to be trained in the Culinary Arts. While our initial pilot programing for culinary students has grown, this new funding will give students in the program access to internships and certifications offered by the American Culinary Federation Education Foundation (ACFEF).

"We are pleased to have qualified for Department of Labor funding based on the quality of our programming and the need in our community. I've seen firsthand how it provides opportunities for so many young people, giving them a second chance to succeed, find a new sense of self and secure a sustainable job or access to future education,"said Community Teamwork CEO Karen N. Frederick.

Congresswoman Niki Tsongas took to social media,"Wishing a big congratulations to Community Teamwork, Inc. for their successful $1.1 million from the US Department of Labor for Youth Build grant which will help to empower the Merrimack Valley's youth with job skills and education in the construction and manufacturing sector."

"YouthBuild isn't just about helping individuals; it's about building a better community," Tsongas said.

# ភេរវកម្មគ្មានមុខសញ្ញាបាញ់រះលើ“ខនសឺត”ដែលមានមនុស្សច្រើន

**ឡាស់វេហ្គាស:** ជនចំណាស់៦៤ឆ្នាំម្នាក់ បានបាញ់រះប្រហារលើទស្សនិកជនដែលមកកំសាន្តជាមួយក្រុមភ្លេង"ខោនទ្រី"ដ៏ល្បីឈ្មោះ នៅសណ្ឋាគារ"ម៉ង់ដាឡេ" នារាត្រីទី៣តុលា ឆ្នាំ២០១៧ បណ្តាលឱ្យមានស្លាប់៥៨នាក់ និងរបួសជាង៥០០នាក់ ។ ភេរវកររូបនេះបានបាញ់សម្លាប់ខ្លួនឯង មុនពេលដែលក្រុមប៉ូលិសបានទៅដល់, ជននោះឈ្មោះ ស្តេហ្វិន ប៉ាដឹក ។ គេសង្ស័យថាអ្នករួមគំនិត ជានារីម្នាក់ដែលគេចាប់បាននៅបន្តិចក្រោយមក ឈ្មោះ ម៉ារីលូ ដាន់លី អាយុ៥៦ឆ្នាំ នៅទីកន្លែងមួយ ដែលនារីនោះនិយាយប្រាប់ប៉ូលិសថា "ខ្លួនមិនបានដឹងអ្វីទេ ពីព្រោះនាងមានជម្លោះជាមួយស្តេហ្វិន ហើយគេបានបណ្តេញនាងឱ្យចេញទៅឆ្ងាយពីគេ ពីបន្ទប់នៃសណ្ឋាគារកាស៊ីណូ" នាថ្ងៃកើតហេតុនោះ។

គ្រាប់កាំភ្លើងបានបាញ់រះ លើក្រុមអ្នកទស្សនារាប់ពាន់នាក់ ពីបន្ទប់ជាន់ទី៣២ ដែលជាបន្ទប់លាក់ខ្លួនរបស់ស្តេហ្វិន ប៉ាដឹកគ្មាននរណាដឹងថាគ្រាប់មកពីណាទេ តែមនុស្សដួលស្លាប់ឈាមហូរព្រោងព្រាត ស្នូរបាញ់រះច្រើននាទីមុននឹងស្ងប់ទៅវិញ ហើយបន្សល់នូវសម្រែកថ្ងូរនឹងយំនៃអ្នករងគ្រោះដែលបណ្តាលមកពីទស្សនិកជនស្លាប់នឹងរបួសរាប់មិនអស់នៅក្នុងសណ្ឋាគារផ្កាយ៥ ដែលជាកាស៊ីណូនោះ។

គេនៅមិនទាន់ដឹងពីមូលហេតុនៃការបាញ់ប្រហារនោះនៅឡើយទេ មកដល់ថ្ងៃអង្គារទី៣នេះ ថាជា"ភេរវកម្ម" ឬក៏ជាទង្វើនៃមនុស្សជម្ងឺសរសៃប្រសាទ? គ្រួសារអ្នករងគ្រោះជាច្រើន មិនអស់ចិត្តឈឺចាប់បានទាមទារឱ្យគេរឹបអូសទ្រព្យសម្បត្តិ ស្តេហ្វិនទាំងអស់ ។ ស្តេហ្វិនធ្លាប់ជាអ្នកធ្វើការនៅក្រសួងប្រៃសនីយ៍តែក្រោយមកក៏បានលាឈប់ទៅធ្វើជាអ្នកទិញលក់ដីលក់ផ្ទះរកលុយបានច្រើន តែចូលចិត្តល្បែងនៅកាស៊ីណូណាស់ ជាអ្នកលេងធំមានផ្ទះនៅច្រើនកន្លែង ។ ស្តេហ្វិនទើបនឹងបានជួបនាង ម៉ារីលូ យកជាគូកំណាន់ ហើយឱ្យលុយទៅទិញផ្ទះមួយ... ដែលធ្វើឱ្យនាងសប្បាយចិត្តណាស់។ នៅថ្ងៃកើតហេតុ ម៉ារីលូ មិនបានចាប់ភ្លឹកថាមានអ្វីចម្លែកក្រៅតែពិការទាស់សម្តីគ្នាបណ្តាលឱ្យមានការបណ្តេញចេញពីបន្ទប់សណ្ឋាគារនោះទេ។








នៅពេលស្លាប់ ស្តេហ្វិន មានកាំភ្លើងច្រើន ដើមនៅជាប់នឹងខ្លួន, តាមការស្រាវជ្រាវរបស់ប៉ូលិសស្តេហ្វិនចូលចិត្តទៅទិញកាំភ្លើងមកបាញ់លេងកំសាន្តតែក៏គេនៅមិនទាន់រកឃើញនូវបុព្វហេតុនៃចំណូលចិត្តប្រើកាំភ្លើងរបស់ស្តេហ្វិននៅឡើយទេ។ ស្តេហ្វិនជាមនុស្សស្ងៀមស្ងាត់មានចរិកជាមនុស្សមិនចុះចាញ់នរណាងាយៗទេ ។ ក្រុមភេរវករ"រដ្ឋអ៊ីស្លាម"បានប្រកាសពីថ្ងៃពុធថា ការបាញ់រះនោះជាស្នាដៃរបស់ពួកគេតែពុំមាននរណាជឿសម្តីនោះបាននៅឡើយទេ ដោយសារគេមិនទាន់រកឃើញភាពទាក់ទងជាមួយ "រដ្ឋអ៊ី ស្លាមអាយស៊ីស"របៀបណានោះនៅឡើយទេ -ការស៊ើបអង្កេតរបស់ប៉ូលិសនៅតែបន្ត៕



# ឱកាសបណ្តុះបណ្តាលផ្នែកផលិតកម្មជាន់ខ្ពស់ បើកចុះឈ្មោះដោយឥតគិតថ្លៃនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលមុខរបរឡូវែល

**ការសិក្សាចាប់ផ្តើមនៅថ្ងៃទី ៣០ ខែតុលា**

**ដោយ សុបិន ពិន**

អាជីពធ្វើការនៅក្នុងការផលិតតាមបែបទំនើប គឺមានភាពខុសគ្នាច្រើនជាងការងារកាលពីសម័យមុន។ លោក Shannon Norton នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលមុខរបរឡូវែលបានមានប្រសាសន៍ថា "វាមិនមែនជាការងារដែលធុញទ្រាន់និងនៅកន្លែងដែលសម្លេងខ្លាំងៗដែលធ្លាប់មានពីមុននោះទេ ប៉ុន្តែអ្វីៗទាំងអស់ គឺត្រូវបានគេប្រើប្រព័ន្ធកុំព្យូទ័រហើយវាមានលក្ខណៈទំនើប និងទាន់សម័យតែស្មុកស្មាញ"។

ដោយសារបច្ចេកវិជ្ជាទំនើប, បច្ចេកទេសក្នុងការផលិតបានផ្លាស់ប្តូរយ៉ាងច្រើនដែលកម្មករត្រូវចេះវិធីក្នុងការអានកូដកុំព្យូទ័រនិងលេខពិសេសដើម្បីអាចធ្វើការនៅក្នុងរោងចក្រមិនគ្រាន់តែធ្វើការដោយប្រើដៃនៅលើខ្សែរចង្វាក់ដំឡើងប៉ុណ្ណោះទេ។

ដោយមានការផ្លាស់ប្តូរបច្ចេកវិជ្ជានេះហើយ វាបានប្រែក្លាយជាឧបសគ្គមួយសម្រាប់ពលករក្នុងការធ្វើការងារ។ ក្រសួងការងារបានផ្តល់ថវិកាដល់វគ្គបណ្តុះបណ្តាលផ្នែកផលិតកម្មជាន់ខ្ពស់ដែលផ្តល់ឱកាសសម្រាប់អ្នកដែលគ្មានការងារ និងអ្នកកំពុងតែមានការងារធ្វើរួចហើយដែលមានឧបសគ្គក្នុងការស្វែងរកការងារដើម្បីទទួលបានវិញ្ញាបនប័ត្រខាងផ្នែកមូលដ្ឋានគ្រឹះគ្រឿងម៉ាស៊ីន ឬមូលដ្ឋានគ្រឹះគ្រឿងអេឡិចត្រូនិច។ វគ្គបណ្តុះបណ្តាលនេះ គឺមានរយៈពេល៦ខែ។ បន្ទាប់ពីបញ្ចប់ការសិក្សាបេក្ខជននឹងមានឱកាសធ្វើការក្នុងវិស័យដូចជា ធ្វើយន្តហោះ, គ្រឿងសពាវុធ, ឧបករណ៍ពេទ្យ, កុំព្យូទ័រ និងអេឡិចត្រូ, ឱសថ និងបរិក្ខាពេទ្យ។ លោក Shannon Norton បានមានប្រសាសន៍ថា "ពួកគេអាចចាប់ផ្តើមធ្វើការងារក្នុងកម្រិតដំបូងសិន ហើយអាចបន្តដល់កម្រិតជាវិស្វករបាន"។

ប្រាក់ឈ្នួល គឺចាប់ពី $16-$30 ក្នុងមួយ

**តទៅទំព័រទី ២១**




Shannon Norton, Executive Director of Career Center of Lowell

# Advance Manufacturing Training Opportunity is Open for Free Enrollment at the Lowell Career Center

## Class Starts on October 30

By Soben Pin

The career in modern manufacturing is much more different than it used to be in the past. "It is not the tedious work and loud noises that how it used to be but everything is computerized and is very sophisticate" says Shannon Norton, the Executive Director of the Career Center of Lowell.

Because of the modern technology, the manufacturing techniques have changed so much that the workers would need to know how to read special computer codes and numbers in order to work in the manufactures, not just working manually on the assembly lines.

With this technological changes, it has become a barrier for eligible workers to work. The Department of Labor funds the Advance Manufacturing Training which provides the opportunity for the eligible unemployed and underemployed workers with employment barriers to earn certificates in Basic Machining or Basic Electronics. The training program is 6 months. After graduation, the candidates would have opportunity to work in the fields such as Aerospace, Defense, Medical Device, Computer & Electronic, Pharmaceutical and Medicine. "They may start working as an entry level and could excel as far as an engineer" says Shannon Norton.

The salary is ranged from $16-$30 per hour with benefits.

"In fact, the career in advance manufacturing in and around Lowell is in so high demands now that companies are constantly in the shortage of workers" says Nancy Gagnon, Career Center Manager.

According to Wanted analytics over the last year in Greater Lowell area there have been over 580 employment opportunities for skilled technicians and engineers and 190 Entry level production related occupations in various manufacturing companies. These companies include Pharmaceutical, Medicine, Medical Equipment supplies, Cutlery,



Nancy Gagnon, Program Manager

Hand Tools, Semiconductor, Electronic Components and Electrical Equipment manufacturing.

The manufacturing companies throughout the Greater Lowell Workforce Area employeapproximately 16,000 employees in various manufacturing related occupations. Some of these companies include: Zell Medical, MA/COM, Nova Biomedical, Four in One, Pace Industries, Thermo Fisher, Raytheon, Enterprise, Lantheus Medical, Analog Devices, Cabot Corporation and United Technologies.

To be eligible for this program the candidates must be between 18-29 years old age, have a HS Diploma, GED or HiSET; Permanent Resident legally eligible to work in US, and must test at 8th grade level in math and reading in English; or be English proficient and have related work experience.

Contact Nancy Gagnon at 978-805-4734, or nancy.Gagnon @cclowell.org to register for upcoming class start on October 30.

# សិទ្ធិស្របច្បាប់ក្នុងការទទួលបានការអប់រំ និងសេវាសុខភាពរបស់ជនអន្តោប្រវេសន៍

**ប្រែសម្រួលដោយ ខ្មែរផុស ស.រ.អ**

**បូស្តុន**- ការិយាល័យអគ្គមេធាវីរដ្ឋម៉ាសាជូសេតបានចេញប្រកាសកាលពីខែឧសភានេះនូវសេចក្តីណែនាំមួយដល់មណ្ឌលថែទាំសុខភាព និងសាលារៀនរដ្ឋទាំងអស់ស្តីពីការអនុវត្តន៏ច្បាប់អន្តោប្រវេសន៍ និងការស្នើរសុំព័ត៌មានពីភ្នាក់ងារអនុវត្តច្បាប់អន្តោប្រវេសន៏ និងគយ (ICE) ។

សេចក្តីណែនាំនេះ គឺក្នុងគោលបំណងរំលឹកដល់សាលារដ្ឋទាំងអស់ពីកាតព្វកិច្ចរបស់ពួកគេតាមច្បាប់រដ្ឋ និងសហព័ន្ធក្នុងការផ្តល់ឱ្យសិស្សទាំងអស់ឱ្យទទួលបានដោយស្មើរភាពនូវការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សាដោយមិនគិតពីជាតិសាសន៏ និងអន្តោប្រវេសន៏។

បើយោងតាមសេចក្តីណែនាំនេះ ឪពុកម្តាយមិនគួរខ្លាចក្នុងការបញ្ជូនកូនៗទៅសាលារៀនហើយពលរដ្ឋទាំងអស់មិនគួរខ្លាចផងដែរក្នុងការស្វែងរកការព្យាបាល ឬសេវាសុខាភិបាលសម្រាប់សមាជិកគ្រួសាររបស់ខ្លួន។

តាមគោលនយោបាយថ្មីនេះភ្នាក់ងារអនុវត្តច្បាប់អន្តោប្រវេសន៏ និងគយ (ICE) មិនធ្វើសកម្មភាពអនុវត្តច្បាប់របស់ខ្លួនដូចជាការឃ្លាំមើល, ការសម្ភាសន៏, ការស្វែងរក និងការចាប់ខ្លួននៅតាមទីតាំងជាក់លាក់មួយចំនួនដូចជាមន្ទីរពេទ្យ, បរិវេណសាលា, ទីតាំងដែលមានសកម្មភាពរបស់សាលារៀន, ទីតាំងចំណតរថយន្តក្រុងក្នុងកំឡុងពេលមានវត្តមានក្មេងៗ, ទីកកន្លែងផ្តល់សេវាសុខភាពដូចជាការិយាល័យវេជ្ជបណ្ឌិត, ខ្លីនិច និងកន្លែងសង្គ្រោះបន្ទាន់ជាដើមនោះឡើយ ។

គោលបំណងនៃច្បាប់នេះ គឺដើម្បីធានាថាពលរដ្ឋដែលកំពុងស្វែងរកសេវាសាធារណៈឬដែលចូលរួមក្នុងសកម្មភាពណាមួយក្នុងរដ្ឋម៉ាសេជូសេតអាចធ្វើទៅបានដោយរលូន និងគ្មានការភ័យខ្លាច ។

សេចក្តីការណែនាំនេះ គឺបង្ហាញយ៉ាងច្បាស់ថា មណ្ឌលថែទាំសុខភាពមិនត្រូវសាកសួរព័ត៌មានអំពីស្ថានភាពអន្តោប្រវេសន៏របស់អ្នកជំងឺនោះទេហើយមន្ទីរពេទ្យទាំងអស់ត្រូវតែប្រតិបត្តិ, ផ្តល់សេវាសង្គ្រោះបន្ទាន់ និងព្យាបាលពួកគេដោយមិនគិត និងសួរអំពីស្ថានភាពអន្តោប្រវេសន៏ ឬធានារ៉ាប់រងរបស់ពួកគេឡើយ ។

ចំពោះសាលារៀនរដ្ឋវិញ សាលាមិនត្រូវសាកសួរអំពីស្ថានភាពអន្តោប្រវេសន៏របស់សិស្សហើយត្រូវផ្តល់លទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំដល់សិស្សទាំងអស់ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៏នោះឡើយ ។

ការផ្សព្វផ្សាយនៃសេចក្តីណែនាំនេះគឺមានសារៈសំខាន់សម្រាប់ជាការយល់ដឹងរបស់ពលរដ្ឋដែលជនអន្តោប្រវេសន៏មករស់នៅក្នុងសហរដ្ឋអាមេរិកពីសិទ្ធក្នុងការទទួលបានការអប់រំសម្រាប់កូនចៅ និងសេវាសុខភាពពេលមានជំងឺ ៕





# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
## Home Care Agency
### Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។




ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហ៊ែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# បទសម្ភាសន៍លោក ហុង លីម តំណាងរាស្ត្ររដ្ឋវិកតូរីយ៉ា

**ខ្មែរផុសស.រ.អា.**

មកពីប្រទេសអូស្ត្រាលីលោក ហុង លីម តំណាងរាស្ត្ររដ្ឋ"វិចតូរីយ៉ា"តាំងពី២២ឆ្នាំមកហើយ, លោកបានមកធ្វើទស្សនកិច្ចនៅទីក្រុងឡូវែលរដ្ឋ "ម៉ាសាឈូសិត" កាលពីថ្ងៃទី៣០កញ្ញា-១តុលា ២០១៧ តាមសេចក្តីអញ្ជើញរបស់បណ្តាញគណបក្សសង្គ្រោះជាតិ ដើម្បីមកជួបប្រជាពលរដ្ឋខ្មែរនៅតំបន់ផ្សេងៗនាសហរដ្ឋអាមេរិកនឹងឡូវែលផង ។ លោកបានផ្តល់បទសម្ភាសន៍មួយដល់កាសែតខ្មែរផុស ដែលមានលំនាំដូចតទៅ:

**ពិន សំខុនៈ** ជម្រាបសួរលោក ហុង លីម, គឺជាកិត្តិយសណាស់ ដែលបានជួបសម្ភាសន៍នឹងលោក នឹងក៏ជាកិត្តិយសដល់ក្រុងឡូវែលដែលបានទទួលលោកជាដំណាងរាស្ត្រដើមកំណើតខ្មែរនៃប្រទេសសេរីដ៏ធំមួយ គឺអូស្ត្រាលីលើទឹកដីអាមេរិកទីដែលសម្បូរខ្មែររស់នៅទីនេះផង។ ខ្ញុំចង់ដឹងណាស់ ថាតើលោកធ្វើយ៉ាងណា ដើម្បីឱ្យបានឡើងដល់ដំណែងដ៏ខ្ពង់ខ្ពស់ជាតំណាងរាស្ត្រនៅទីនោះបាន?

**ហុង លីមៈ** បាទជម្រាបសួរ, គឺជាសំណាងរបស់ខ្ញុំ ដែលបានទទួលដំណែងនេះ ហើយក៏ជាការខិតខំរបស់ខ្ញុំនឹងរបស់ប្រជាពលរដ្ឋខ្មែរយើងផងដែរ ទើបខ្ញុំបានជាប់ជាតំណាងរាស្ត្ររបស់គណបក្សពលករ"Labor Party"ដែលជាគណបក្សដ៏សំខាន់នៅរដ្ឋ"វិចតូរីយ៉ា"នេះ តែបើនៅសហព័ន្ធទីក្រុង"កំប៊ែរ៉ា"វិញ គណបក្សពលករជាគណបក្សភាគតិច។ នៅពេលខ្ញុំរៀនចប់ថ្នាក់បរិញ្ញាខាងវិទ្យាសាស្ត្រនយោបាយនឹងសាលារដ្ឋបាលនៅក្រុងរបស់ខ្ញុំ នាឆ្នាំ១៩៧០ ខ្ញុំមិនអាចទៅកម្ពុជាវិញបានទេ ដោយស្រុកយើងមានសង្គ្រាម ខ្ញុំក៏មកបន្តថ្នាក់"ម៉ាស្ទ័រ"នៅវិចតូរីយ៉ា ចំពេលដែលមានក្រុមអ្នកភៀសខ្លួនច្រើនមកដល់ គេត្រូវការឱ្យខ្ញុំអ្នកជួយជាបន្ទាន់ ម្លោះហើយខ្ញុំក៏ក្លាយជាអ្នកជួយជនភៀសខ្លួនជាច្រើនឆ្នាំធ្វើតាំងពីរកទីជម្រកដូចជាពីដើមយើងធ្លាប់មានផ្ទះតែរៀងៗខ្លួនមកដល់ស្រុកគេត្រូវជួលផ្ទះមិនចេះមើលកិច្ចសន្យា -រកប្រាក់ជំនួយ -រកសាលាឱ្យកូននឹងឱ្យខ្លួនឯងរៀន -ត្រូវការធ្វើបុណ្យឱ្យមនុស្សស្លាប់គ្មានលោកសង្ឃគ្មានវត្ត ម្លោះហើយត្រូវបង្កើតវត្ត -ធ្វើការចូលសញ្ជាតិនៅឯណោះ តែ២ឆ្នាំចូលសញ្ជាតិបានហើយ...



**ពិន សំខុនៈ** តើពេលណាលោកចូលមកក្នុងឆាកនយោបាយ?

**ហុង លីមៈ** គឺជាការចៃដន្យមួយដែលនៅពេលចុះទៅជួយជនភៀសខ្លួន ក៏ពេលខ្លះអ្នកនយោបាយខ្វះអ្នកកាន់បដារឃោសនា គេក៏ហៅខ្ញុំឱ្យជួយកាន់...ហើយពេលនោះការបោះឆ្នោតគេបោះឆ្នោត១ឆ្នាំម្តង (ឥឡូវគេដូរហើយ បោះឆ្នោត៤ឆ្នាំម្តង) ធ្វើឱ្យខ្ញុំស្គាល់អ្នកនយោបាយកាន់តែច្រើន ពួកគេក៏បានសួរខ្ញុំថា "អ្នកកាន់បដារឱ្យគេច្រើនហើយ តើមានទឹកថានឹងកាន់បដាររបស់ខ្លួនឯងថ្ងៃណាមួយទេ?" ខ្ញុំយល់ភ្លាមថា "ឱកាសបានមកដល់ឱ្យខ្ញុំធ្វើនយោបាយហើយ គេទំនងជាបានសម្លឹងខ្ញុំជាបេក្ខជនដ៏សមរមសម្រាប់តំបន់ហើយ"... នៅតំបន់នោះ គណបក្សពលករខ្លាំងណាស់ "គេដាក់បេក្ខជនរបៀបឆ្កែឆ្មាអីក៏ជាប់ដែរ ខ្ញុំក៏យល់ព្រម!" តំបន់ខ្ញុំ ជាតំបន់នៃប្រជាជនភាគតិចអតីតជនភៀសខ្លួនដល់ទៅ៥៨% ពួកស្បែកស "អង់គ្លោសាក់សុង"មានតែ៤០%ទេ ហើយក្នុង ៥៨%នោះ សាសន៍ចម្រុះប្រមាណជា៩០សាសន៍ឯណោះ សម្បូរខ្មែរ ឡាវ វៀតណាម មង... ដែលជាហេតុបានជាខ្ញុំជាប់ឆ្នោតជាតំណាងរាស្ត្រនៅរដ្ឋវិកតូរីយ៉ាពេលនោះទៅ ហើយខ្ញុំក៏ជាជនអាស៊ី

តទៅទំព័រទី១១







តមកពីទំព័រទី ១០

## បទសម្ភាសន៍លោក ហុង លីម តំណាង...

ដំបូងបង្អស់ដែលបានជាប់ឆ្នោតជាតំណាងរាស្ត្រ នៅរដ្ឋវិកតូរីយ៉ា របស់ប្រទេសអូស្ត្រាលី...

**ពិនសំខុន:** នៅក្នុងនយោបាយនៅរដ្ឋ "វិកតូរីយ៉ា" តើកម្លាំងនយោបាយរបស់គណបក្សលោកធំប៉ុណ្ណា បានជាលោកហាក់ដូចជានិយាយពីកម្ពុជារបស់លោក ហ៊ុន សែន ម្តងៗ ឥតមានញញើតមាត់ តើមិនប៉ះពាល់ដល់អារម្មណ៏អ្នកនយោបាយឯទៀតៗទេឬ?

**ហុង លីម:** អត់ប៉ះអីទេ! អូស្ត្រាលីជាស្រុកមានសេរីភាពនរណាចង់និយាយអ្វីក៏និយាយទៅ... នៅសភាគេរៀបចំធ្វើច្បាប់មាន២ជាន់ គឺ "សភាជាន់ក្រោម- Lower House" សម្រាប់ធ្វើជារដ្ឋាភិបាលផង ជាសភាស្នើ-ពិភក្សា-អនុម័តច្បាប់-បញ្ជូនទៅ"សភាជាន់ខ្ពស់-Upper House" ជាអ្នកសម្រេច: "យល់ព្រម ឬមិនយល់ព្រម"។ គឺសភាជាន់ក្រោមនោះហើយ ជាសភាមានឈ្មោះល្បី មានកម្លាំង ពិភាក្សាច្បាប់ហើយអនុវត្តន៏ច្បាប់... មិនដូចនៅអាមេរិកនេះទេ ដែលព្រឹទ្ធសភា "Senete"គេមានកម្លាំងជាង...

**ពិន សំខុន:** តើគណបក្សពលករជាគណបក្សភាគច្រើនឬ នៅរដ្ឋវិកតូរីយ៉ា?

**ហុង លីម :** បាទយើង (គណបក្សពលករ) ជាគណបក្សមានសម្លេងភាគច្រើន នៅរដ្ឋវិកតូរីយ៉ា ហើយយើងជាអ្នករៀបចំរដ្ឋាភិបាល, ខ្លួនខ្ញុំក៏ជារដ្ឋលេខាធិការរដ្ឋាភិបាលខាងវប្បធម៌ខាងទំនាក់ទំនងអាស៊ីម្នាក់ដែរធ្វើការនៅសភាដូចគ្នា... បើនៅ"កំប៉ែរ៉ា"វិញ គណបក្ស "លីបេរ៉ល" គេមានសម្លេងភាគច្រើន គេកាន់អំណាច... នៅពេលធ្វើបាតុកម្ម ខ្ញុំបានទៅគៀងគរពលរដ្ឋឱ្យមកសម្តែងឆន្ទៈបញ្ចេញមតិឱ្យគេឯងដឹងឱ្យសភាគេចាប់អារម្មណ៏, ជាពិសេសឱ្យ "កំប៉ែរ៉ា" ដែលមានរដ្ឋាភិបាលសហព័ន្ធគេដឹងឮពីការឈឺចាប់របស់យើង... បាតុកម្មរបស់ខ្មែរយើងបានធ្វើឱ្យសមាជិកសភា៨រូបនៅ"កំប៉ែរ៉ា"កក្រើកចេញមកថ្លែងការថ្កោលទោសរដ្ឋាភិបាល ហ៊ុន សែន, ដែលនេះជាសញ្ញាឱ្យក្រសួងកិច្ចការបរទេសអូស្ត្រាលីមានជំហ៊រការពារប្រជាពលរដ្ឋខ្មែរ ហើយដាក់សម្ពាតលើ ហ៊ុន សែន បាទ... នៅស្រុកគេប្រព័ន្ធធ្វើការរបស់គេ គឺប្រធាននៃគណបក្សប្រឆាំង គឺជាអនាគតនាយករដ្ឋមន្ត្រីនៃប្រទេសរបស់គេនៅពេលដែលគណបក្សប្រឆាំង គេទទួលសម្លេងភាគច្រើនទៅវិញ, គេមិនដែលព័ទចាប់ប្រធានគណបក្សប្រឆាំងទាំងយប់ ហើយមិនដឹងជាមានអ្វីសម្រាប់ចោទប្រកាន់គេរបៀបហ្នឹងទេ ធ្វើរបៀបនេះធ្វើឱ្យគេភ្ញាក់ផ្អើលទាំងសកលលោក...

**ពិន សំខុន:** លោកបាននិយាយថា បាតុកម្មរបស់ពលរដ្ឋដើមកំណើតខ្មែរមានឥទ្ធិពល លើអ្នកមានអំណាចនៅអូស្ត្រាលី តើមានអំណាចរបៀបណា?

**ហុង លីម:** ខ្ញុំបានអញ្ជើញតំណាងសហគមន៏ខ្មែរពីគ្រប់កន្លែងនឹងមានតំណាងវត្តមានព្រះសង្ឃ៣អង្គ ឱ្យមកសម្តែងការមិនសប្បាយចិត្តនៅចំពោះមុខប្រធាននៃគណបក្សប្រឆាំងនៅ"កំប៉ែរ៉ា" គឺប្រធានរបស់ខ្ញុំហ្នឹងឯង ដែលជាអនាគតនាយករដ្ឋមន្ត្រីដែលគេនឹងទៅកាន់ដំណែងពេលគេឈ្នះឆ្នោតលោកមានសិទ្ធិនឹងទិទៀននាយករដ្ឋមន្ត្រីកាន់អំណាច ប្រសិនបើនៅកាន់ជើង ហ៊ុន សែន, រួចនាំគ្នាទៅប្តឹងដល់រដ្ឋមន្ត្រីកិច្ចការបរទេសនៃរដ្ឋាភិបាលស្រមោលនៅក្នុសភាហ្នឹង...

**ពិន សំខុន:** អ្វីទៅដែលលោកហៅថារដ្ឋមន្ត្រីកិច្ចការបរទេសនៃរដ្ឋាភិបាលស្រមោល?

**ហុង លីម:** នៅសភាអូស្ត្រាលី រដ្ឋាភិបាលស្រមោល គឺជាអ្នកដែលមានភារកិច្ចតាមដានក្រសួងនិមួយៗហើយទិទានជាសាធារណៈបាននៅពេលធ្វើអ្វីខុសនិមួយៗ ពិរដ្ឋសភាទៅ, គឺអ្នកនោះឯងហើយ ដែលនឹងទៅកាន់ដំណែងដ៏មានអំណាចនោះនៅពេលដែលគណបក្សខ្លួនឈ្នះឆ្នោតវិញ, អីចឹងខ្ញុំនាំលើកគ្នាទៅប្តឹងក្រសួងការបរទេសនៃរដ្ឋាភិបាលស្រមោលក្នុងគណបក្សខ្ញុំហ្នឹង គឺដូចជាខ្ញុំទៅប្តឹងសារទុក្ខនៅក្រសួងការបរទេសនៃរដ្ឋាភិបាល"កំប៉ែរ៉ា"ដែរ ពីព្រោះគេធ្វើការក្នុងនយោបាយដោយពិគ្រោះគ្នា ឬក៏ប្រជែងគ្នា... នៅស្រុកខ្មែរ គណបក្សប្រឆាំងបែរជាមិនអាចទិទៀនរដ្ឋាភិបាលដែលជាតួនាទីចំបងរបស់គេទៅវិញ ចោទគេថាក្បត់ជាតិ...វាមិនត្រូវទេ!

**ពិនសំខុន:** នៅពេលមកដល់សហរដ្ឋអាមេរិក តើលោកមើលឃើញនឹងចាប់អារម្មណ៏យ៉ាងណាដែរ ចំពោះសកម្មភាពពលរដ្ឋខ្មែរអាមេរិកាំង?

**ហុង លីម:** ខ្ញុំបានឃើញថា បងប្អូនយើងមានការយកចិត្តទុកដាក់ខ្លាំងចំពោះវាស្នាជាតិខ្មែរយើង ដែលកំពុងឆ្លងកាត់ការគ្រោះថ្នាក់ ដែលរដ្ឋាភិបាលចង់នាំប្រទេសកម្ពុជាត្រឡប់ទៅរករបបផ្តាច់ការវិញ បើចង់ធ្វើអីចឹង ម៉េចក៏មិនទៅនៅរស្រុកយួនតែម្តងទៅ! ពលរដ្ឋខ្មែរឥតត្រូវការរបៀបហ្នឹងទេ! ខ្ញុំឃើញបងប្អូនបានអញ្ជើញមកទទួលខ្ញុំយ៉ាងរាក់ទាក់ ហើយច្រើនរយនាក់បានមកស្តាប់វេទិការសាធារណដែលខ្ញុំបានធ្វើជូនកាលពិម្សិលមិញ ធ្វើឱ្យខ្ញុំមានមោទនភាពណាស់, ច្រើនគ្នាបានទូរស័ព្ទមកក្នុងកម្មវិធីសួរឆ្លើយតាមទូរទស្សន៏ គឺជាការចេះប្រើសិទ្ធសេរីភាពប្រើលទ្ធិប្រជាធិបតេយ្យនៅពេលមានបងប្អូនច្រើនរូបបានឈរឈ្មោះឱ្យគេបោះឆ្នោតធ្វើជាសកាជិកក្រុមប្រឹក្សាសាលាក្រុងក្រុមប្រឹក្សាសាលារៀន... ខុសគ្នាពី ហ៊ុន សែន ដែលគាត់បិទកាសែត បំបិទវិទ្យុ ទូរទស្សន៏ដែលប្រឆាំងនឹងគាត់... គឺយើង

តទៅទំព័រទី ១២






## តមកពីទំព័រទី ១១ បទសម្ភាសន៍លោក ហុង លីម តំណាង...

ចង់ឱ្យមានការគ្រប់គ្រងបែបសេរីចង់ធ្វើមានរចនាសម្ព័ន្ធរបៀបនេះនៅកម្ពុជាដែរ ។

**ពិន សំខុន:** បងប្អូនខ្មែរជាច្រើនបានចាកចេញពីកម្ពុជាមករស់នៅឯបរទេស ចុះរូបលោក





អញ្ជើញចេញពីតំបន់ណានៃប្រទេសកម្ពុជា?

**ហុង លីម:** ខ្ញុំនៅស្រុកស្អាង ខេត្តកណ្ដាល ឃុំព្រែកគយ...ខ្ញុំបានត្រឡប់ទៅមើលស្រុកភូមិកំណើតខ្ញុំតែបានបាត់បង់អស់ហើយមិនដូចដើមទេ...គ្មានបងប្អូនខ្ញុំណាត្រឡប់ទៅវិញទេ តែស្រុកស្អាងមានប្រពៃណីមួយ គឺមិនចុះញ៉មទេ ខ្សែវសំផន អី១ចេញពីហ្នុង!.... មានមេស្រុក កោះធំខាងគណបក្សប្រជាជននៅជាប់គ្នាហ្នុងគាត់ថាអ្នកស្រុកគាត់ ហៅមកប្រជុំគាត់មក... ហៅឱ្យលុយក៏យក... ដល់បោះឆ្នោតបោះឱ្យសង្គ្រោះជាតិអស់...ចំណែកស្អាងវិញ ក្នុង១១ឃុំយកអស់១០ឃុំហើយ... កាលនៅស្រុកខ្មែរ ខ្ញុំបានទៅរៀនសាលាអង់គ្លេស ហើយដោយសាចេះលើសគេតែភាសាអង់គ្លេសនោះ ខ្ញុំក៏ប្រឡងជាប់បានអាហារូបករចេញមករៀននៅអូស្ត្រាលី...

**ពិន សំខុន:** កាសែតខ្មែរផុសយើងមានអាយុ១១ឆ្នាំហើយ មានគេអានច្រើន តើលោកមានសារអ្វីទេសម្រាប់ផ្ញើរទៅជូនអ្នកអានរបស់កាសែតយើងទេ?

**ហុង លីម:** ចំពោះកាសែតលោកប្អូន ខ្ញុំមានមោទនភាពណាស់ នឹងសុំសសើរដែលបានធ្វើឱ្យកាសែតខ្មែររស់បាន១១ឆ្នាំ នៅបរទេសជាការលំបាកខ្លាំងណាស់...ខ្ញុំនៅអូស្ត្រាលីឯណោះកាសែតកើតហើយស្លាប់ កើតហើយស្លាប់លោកប្អូនធ្វើហើយ រស់បាន១០ឆ្នាំទៅហើយ ខ្ញុំមានសេចក្ដីត្រេកអរណាស់ ហើយនឹងនាំដំណឹងនេះទៅប្រាប់បងប្អូនយើងនៅឯនាយ, ហើយសូមឱ្យបងប្អូនឯណោះបន្តជួយគាំទ្រកាសែតខ្មែរនេះឱ្យរស់បន្តបានយូរអង្វែងសម្រាប់ជាកិត្តិយសដល់សហគមន៍ខ្មែរយើង... ហើយដែលទូលំទូលាយជាងនេះទៅទៀត សូមឱ្យបងប្អូនបង្កើនការយកចិត្តទុកដាក់ថែមទៀត ពីព្រោះស្រុកខ្មែរយើងកំពុងតែឆ្លងគ្រោះថ្នាក់ខ្លាំងណាស់ ហ៊ុន សែនចង់បំបាត់លទ្ធិប្រជាធិបតេយ្យបំបាត់សេរីភាពជាការគួរឱ្យឈឺចាប់ណាស់... ហេតុដូច្នេះហើយការចេញទៅបោះឆ្នោតជាការសំខាន់ណាស់សម្រាប់ផ្លាស់ប្តូរជីវិតបងប្អូនសម្រាប់ជីភាពប្រសើរ សូមឱ្យប្រាប់ទៅបងប្អូនដែលនៅឯស្រុកខ្មែរឱ្យទៅចុះឈ្មោះបោះឆ្នោតនឹងចេញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា... សុខ ឥសាន និយាយថាបងប្អូនចាកស្រុកទៅធ្វើការស្រុកគេ គឺបានលុយច្រើន...និយាយគ្មានដឹងអីសោះ...ចាកស្រុកទៅធ្វើការស្រុកគេចំណេញតែស្រុកគេទេ ហើយបើសិក្សាធិការសិស្សរៀនតែកន្លះថ្ងៃទៅប្រជែងនឹងក្មេងអាស៊ានយ៉ាងម៉េចនឹងបាន? ឥឡូវចាស់ខ្មែរមានកូនខ្ចីអស់ហើយ! គួរឱ្យអាណោចអាធម្មណាស់ ព្រោះអីកូនៗចេញទៅធ្វើការស្រុកក្រៅគេទុកចៅឱ្យយាយតាមើល! ដូច្នេះត្រូវតែឱ្យមានការផ្លាស់ប្តូរនៅស្រុកយើង ទើបបាន! មិនអាចទុកពេទ្យទុកសិក្សាធិការទុកជីវិតពលរដ្ឋឱ្យនៅរបៀបនេះតទៅទៀតទេ! ខ្ញុំមកនេះ សូមអំពាវនាវឱ្យបងប្អូន "ធ្វើចលនាតវ៉ាក្នុងសម្លេងតែមួយពេលតែមួយនៅជុំវិញពិភពលោក" ដើម្បីរំដោះឱ្យបងប្អូនខ្មែរយើងបានរួចពីទុក្ខទោសដែលគម្រាមកំហែងដោយរបបតិរិច្ឆានរាល់តែថ្ងៃ ៕

LOWELL COMMUNITY HEALTH CENTER
Caring for Lowell. Caring for You.

- Metta Health Center - Primary Care
  មណ្ឌលមេត្តាសុខភាព–មន្ទីរពេទ្យប្រចាំគ្រួសារ
- Behavioral Health Services
  កម្មវិធីសុខភាពផ្លូវចិត្ត
- Teen Programs
  កម្មវិធីសម្រាប់យុវវ័យ
- Domestic Violence Program
  កម្មវិធីអប់រំផ្នែកអំពើហឹង្សាក្នុងក្រុមគ្រួសារ
- Help applying for health insurance
  កម្មវិធីជំនួយដាក់ពាក្យសុំការធានារ៉ាប់រងសុខភាព
- Services in Khmer, Laotian, Burmese, & Nepalese
  កម្មវិធីបម្រើផ្សេងៗ ជាភាសាខ្មែរ ឡាវ ភូមា និងនេប៉ាល់



PHARMACY | ឱសថស្ថាន
Pharmacy hours:
Monday - Friday 8am - 9pm
Saturday - 8:30am - 2:30pm

135 & 161 Jackson Street, Lowell | 978.441.1700 | www.lchealth.org

# ពីរសប្តាហ៍សម្រាប់ជួបក្រុមគ្រួសារនៅប្រទេសបារាំង

**តពីលេខមុន**

ក្នុងដំណើរទៅតំបន់"ន័រម៉ង់ឌី"នេះ យើងមិនចង់ធ្វើដំណើរតាមផ្លូវធំ (HWay)ទេ ពីព្រោះតែគ្មានទេសភាពជាជនបទនៃប្រទេសបារាំងសាមញ្ញនោះ ដូច្នេះយកផ្លូវជនបទជាជម្រើសទេសចរយើងដែលធ្លាប់ស្គាល់តំបន់នេះកាលពី២០ឆ្នាំមុនមកម្លេះ។ ថ្វីត្បិតតែផ្លូវតូច រថយន្តយើងរត់មិនលឿនក្តីផ្លូវនេះមិនបានធ្វើឱ្យយើងធុញទ្រាន់ទេ ពីព្រោះពីតំបន់មួយទៅតំបន់មួយទៀត ទេសភាពមិនដូចគ្នាទេ ហើយប្រវត្តិសាស្ត្រនៃតំបន់ក៏មិនដូចគ្នាដែរ ។ គេអាចឃើញព្រះវិហារចាស់ៗខុសសោភណ្ឌភាពគ្នារចនាបទនៃភូមិឋានក៏ស្របទៅតាមចំណាស់នៃការកកើតភូមិក្រុងដែលជនជាតិបារាំងរស់នៅរាប់ពាន់ឆ្នាំមកហើយ -ពិសេសជាងនេះទៅទៀត ក្រុងនៃតំបន់និមួយៗគេបានតែងលំអរដោយសួនច្បារប្រកបដោយបុប្ផចម្រុះពណ៌នៅជុំវិញ រូបចម្លាក់ ឬបូជនីយដ្ឋានដ៏មានតម្លៃក្នុងប្រវត្តិសាស្ត្រ ឬក្នុងស្នាដៃសិល្បៈជាដើម។

សំដៅទៅទីក្រុង"ដូវីល"ដ៏គួរឱ្យចាប់អារម្មណ៍ជាទីបំផុត នាតំបន់ខាងជើងឈៀងខាងលិច គឺជាតំបន់ទេសចរល្បីល្បាញទាក់ទាញភ្ញៀវដោយសារមានកាសុីណូដ៏ធំជាងគេបង្អស់នាភាគខាងជើងប្រទេសបារាំង( គឺជាកាសុីណូដែលមានដំបូងគេបង្អស់នៅបារាំង ហើយប្រទេសនេះមិនមានកាសុីណូច្រើនដូចអាមេរិកទេ) នឹងមានរមណីយដ្ឋានស្រស់បំព្រងជាច្រើននារដូវក្តៅ។ ភ្ញៀវជាច្រើនទៀត បានស្គាល់ឈ្មោះ "ដូវីល" ដោយសារតែនៅក្នុងតំបន់ឈ្មោះ"ន័រម៉ង់ឌី"តំបន់ដែលបក្សសម្ព័ន្ធអាមេរិកាំង-បារាំង-អង់គ្លេស បានវាយលុកលើទ័ព"អាល្លឺម៉ង់"ចក្រព័ត្រដោយមិនដឹងខ្លួនជាមុន បណ្តាលឱ្យអាល្លឺម៉ង់នៃរបប "ហ៊ីត្លែ" ចាប់ផ្តើមបាក់ទ័ព រហូតដល់ចាញ់សង្គ្រាមលោកលើកទី២ -ហើយ"ដូវិល" ដ៏ល្បីល្បាញម្យ៉ាងទៀតនោះ គឺឋិតនៅក្បែរកំពង់ផែបារាំង "ឡឺអាវ" ដ៏ធំបំផុតមួយនៃភាគខាងជើង,ស្តេចខ្មែរព្រះបាទស៊ីសុវត្ថិ កាលពីជំនាន់បារាំង ក៏បានយាងមកទីក្រុងបារីស ហើយទ្រង់ត្រូវបានចុះចតកុប៉ាល់ជាន់ដីបារាំងជាដំបូងបង្អស់នៅ"ឡឺអាវ"នេះឯង។






យើងបានសំដៅមកបំរុងសម្រាកនៅ"ដូវីល" ដែលនៅចម្ងាយ៣ម៉ោងប៉ុណ្ណោះពីប៉ារីស តែអស័យដ្ឋានសណ្ឋាគាររបស់មិននៅទៅនោះទេ គេបានបញ្ជូនយើងទៅទីក្រុងធំមួយទៀតឈ្មោះ "កាបួ" ដែលយើងត្រូវធ្វើដំណើរបន្ថែមទៀតប្រមាណជាកន្លះម៉ោងទើបបានដល់សណ្ឋាគារ "ឡាក្លូសឺរី" ដែលស្ថិតនៅចំពីមុខមហាសណ្ឋាគារមួយហៅថា"ក្រុងហូតែល" ដែលមានកន្លែងលេងល្បែង"កាស៊ីណូ"តូចមួយទៀត។ យើងមិនបានអស់សង្ឃឹម ឬក៏ខកចិត្តនឹងក្រុងតូចនេះទេ ពីព្រោះជាទីក្រុងដែលប្រកបដោយសោភ័ណ្ឌភាពនៃសួនច្បារធំៗ មានឆ្នេរសមុទ្រសមរម្យមួយដែលមានអ្នកមកលេងទឹកជាហូរហែរ ហើយក៏ជាទីក្រុងដែលមានប្រវត្តិសាស្ត្រជាកំពង់ផែរចាស់មួយដែរ។ នៅទីនោះ យើងចូលចិត្តផ្លូវថ្មើរជើងមួយដែលមានហាងទំនិញនឹងភោជនីយដ្ឋានទំនើបជាច្រើនដែលក្លិនឈ្ងុយនៃកាហ្វេនឹងនុំបារាំងពេលព្រឹកព្រហ៊ាមទ្រាំមិនចូលទៅទិញហូបទប់មិនបាន។ ពេលថ្ងៃយើងទៅកំសាន្តឯឆ្នេរសមុទ្រទឹកសមុទ្រមិនជាថ្លាប៉ុន្មានទេតែប៉ុណ្ណារ៉ូ អាចរកមិត្តលេងជាមួយគ្នាយ៉ាងរីករាយ បើទោះជានិយាយមិនយល់គ្នាក៏ដោយ -ពេលល្ងាចយើងទៅរកហូបម្ហូបគ្រឿងសមុទ្រ ដែល ប៉ុណ្ណារ៉ូ ចូលចិត្តជាងគេនឹងហៅ "ស៊ុបត្រី"ដ៏ល្បីថាជាស្នាដៃអ្នកស្រុក"ន័រម៉ង់ឌី" ឯសូបិនចូលចិត្តហៅ"គ្រុម"ដែលគេលើកម្តងៗ ១ចានគោមបំរើភ្ញៀវម្នាក់ គេធ្វើឆ្ងាញ់របស់គេមែន។

កំដៅថ្ងៃនៃខែកក្កដានៅ"កាបួ"ក្តៅខ្លាំងណាស់ ពេលត្រឡប់ពីដើរលេងខាងក្រៅម្តងៗ ប៉ុណ្ណារ៉ូតែងសុំទៅមុជទឹកនៅអាងហែលទឹករបស់សណ្ឋាគារ"ឡាក្លូសឺរី" ប៉ុណ្ណារ៉ូ តែងតែហែលទៅរកក្មេងៗដូចគ្នា ដើម្បីលេងជាមួយគ្នាមានឪពុក ឬម្តាយគេមកជាមួយកូនគេ, តែកូនបារាំងមិនសូវហ៊ានមកជិត ប៉ុណ្ណារ៉ូ ទេ ដោយនិយាយភាសាខុសគ្នាលេងមិនយល់គ្នាសោះបានត្រឹមតែសើចស្ញេញស្ញាញដាក់គ្នាតែប៉ុណ្ណោះ។ ពេលយប់យើងមិនបាននៅក្រៅលើសពីម៉ោង៩យប់ទេ ដោយសារកន្លែងកំសាន្តមានតែមួយ គឺនៅកាសុីណូដ៏តូចមួយគ្មានអ្វីលេងឱ្យបានរីករាយដូចនៅអាមេរិកទេ ជាទូទៅគេទៅលេងភ្នាល់ជាមួយម៉ាស៊ីនពេលថ្ងៃ,ពេលយប់ទើបមានបើកលេងបៀរលើតុល្បែងដែលគេមានសណ្តាប់ធ្នាប់ច្រើនជាងនៅអាមេរិក។













យើងនៅ"កាបួ"បាន២យប់ រួចយើងក៏ត្រឡប់មកដូរយកសណ្ឋាគារនៅក្រុង"ដូវិល"វិញ ដែលទំនងជាធំជាង ហើយប្រហែលជាសប្បាយជាង "កាបួ"ដែរ៕

# សមាគមខ្មែរប្រជុំសហគមន៍សិក្សាពីអាជីវកម្មអាស៊ី

**ដោយ ខ្មែរផុស ស.រ.អា.**

នាង តារា សុខ ជាម្ចាស់នៃសហគ្រិនផ្តល់សេវាឯកសារពន្ធដារនិង លោក ស៊ុន ម៉ម ជាម្ចាស់ភោជនីយដ្ឋានសំពៅមាសបានមកធ្វើជាវាគ្មិនពិសេសក្នុងកម្មវិធី"E. For All"របស់សមាគមខ្មែរដឹកនាំដោយ ទូច វ៉ាន កាលពីពាក់កណ្តាលខែកញ្ញាវេលាម៉ោង៦ល្ងាច។ កម្មវិធី"E.For all" នោះជាកម្មវិធីសម្រាប់ជួយបង្ហាត់បង្ហាញពលរដ្ឋក្នុងសហគមន៍ឱ្យមានចំណេះគ្រប់គ្រាន់សម្រាប់បើកនឹងគ្រប់គ្រងហាងជាម្ចាស់ការខ្លួនឯងនៅពេលដែលមានជំនាញជាមុខរបរអ្វីមួយហើយ។

អ្នកស្រី វណ្ណា ហូវ៉ាត ជាពិធីករ បានណែនាំឱ្យគេស្គាល់វាគ្មិនរបស់ខ្លួន ហើយក៏អញ្ជើញអ្នកទាំង២និយាយអំពីដំណើរការនៃមុខរបរជូនភ្ញៀវដែលភាគច្រើនជាយុវជនមកស្តាប់សេចក្តីរាយការណ៍របស់វាគ្មិន។

នាង តារា សុខ ទើបនឹងបើកមុខជំនួញមួយខាងធ្វើ"តាក់-Tax" ជូនពាណិជ្ជករនានាដែលត្រូវការអ្នកឯកទេស បន្ទាប់ពីនាងទៅសិក្សាទទួលការណែនាំពីអ្នកឯកទេសក្នុងសមាគមខ្មែរ ដើម្បីឱ្យមានការទុកចិត្តហ៊ានបើកជាមុខជំនួញមួយបានមក។ តារា សុខ បានរៀនចប់មហាវិទ្យាល័យខាងផ្នែកគណនីយ្យបានឃើញកម្មវិធីរបស់សមាគមខ្មែរ មិនត្រឹមតែមិនមានបង់ប្រាក់កំរៃតែប៉ុណ្ណោះទេ ថែមទាំងមានរង្វាន់សម្រាប់ជាដើមទុនបើកហាងរបស់ខ្លួនទៀតផង។

លោក ស៊ុន ម៉ម បានថ្លែងថា "លោកពីដើមកាលពីនៅស្រុកខ្មែរ ជាទាហ៊ានជើងទឹក មកអាមេរិកនេះរស់នៅវីវរធ្វើការឱ្យគេនៅទីនោះ, តែដោយមិនចង់ធ្វើការឱ្យគេតទៅទៀត ក៏សម្រេចចិត្តបើកហាងលក់បន្លែមួយដោយមិនមានដើមទុនអ្វីច្រើនទេ។ ក្រោយមកទៀត ឱកាសបានហុចឱ្យប្តូរមុខរបរបើកបានភោជនីយដ្ឋានមួយទាំងមិនចេះធ្វើម្ហូបផង។ តែដោយការព្យាយាមនឹងតស៊ូក្នុងជីវិតម្តងបន្តិចៗហាងនោះ ក៏ដំណើរការបានរហូតដល់សព្វថ្ងៃ ។




សមាគមខ្មែរបានយកមកបង្ហាញនូវពាណិជ្ជករ២រូប ដែលមានការអប់រំពិមជ្ឈដ្ឋានខុសគ្នាតែធ្វើពាណិជ្ជកម្មបានប្រាក់ចំណេញដូចគ្នា:



**១-**នាង តារា សុខ មានចំណេះវិជ្ជាចេញពីសាលារៀនអាមេរិកាំងជាតំណាងឱ្យយុវជនយុវនារីជាច្រើនដែលធាត់ធំនៅសហរដ្ឋអាមេរិកដែលមានឱកាសបានរៀនសូត្រមុខវិជ្ជាទំនើបដែលមានក្បួនខ្នាត បន្តពីអ្នកសិក្សា អ្នកកត់ត្រាការចងចាំនឹងបទពិសោធន៍មនុស្សច្រើនជំនាន់ ។ យុវជនតែងពឹងពាក់ទៅលើសម្ភារៈបច្ចេកទេសទំនើប ទំនាក់ទំនងនឹងវិជ្ជាខាងទីផ្សារសេរី នឹងប្រជែងគ្នាក្នុងភាពទូលំទូលាយ ។ល។

**២-**លោក ស៊ុន ម៉ម មានចំណេះពាណិជ្ជកម្មតាមការពិសោធន៍ផ្ទាល់ខ្លួនយកជ័យជំនះលើភាពក្រីក្រនឹងការអត់ឃ្លានក្នុងជីវភាពនៃជនភៀសខ្លួន ដោយខ្លួនឯង, ដោយមានការណែនាំបន្ទាប់បន្សំពីអ្នកឯកទេសខ្លះៗផង ដោយដកស្រង់បទពិសោធន៍នៃអ្នកជិតខាងផង ក៏អាចធ្វើការងារចិញ្ចឹមជីវិតបានដែលចំណេះនេះ ជាវិជ្ជាផ្ទាល់ខ្លួនពិបាកនឹងបង្ហាត់បង្ហាញបន្តទៅយុវជនជំនាន់ក្រោយទៀតបាន, គឺជាវិជ្ជារបស់អ្នកមានមុខរបរ នៃមនុស្សជំនាន់ចាស់ ប្រចាំត្រកូល ពីស្រុកកំណើតពឹងទៅលើការព្យាយាម ទៅលើការអត់ធ្មត់ ទៅលើការសន្សំនឹងការចំណាំ។

នៅទីផ្សារអាស៊ីគេតែងសង្កេតឃើញអ្នកមានវិជ្ជាជីវៈទាំង២យ៉ាងនេះ កំពុងប្រកបមុខរបរយ៉ាងមមាញឹកដែលទាក់ទាញភ្ញៀវមិនដូចទីផ្សារបរទេសនោះទេ ឧទាហរណ៍ ដូចជាផ្សារអាស៊ី មានភ្ញៀវយ៉ាងរវល់ នៅថ្ងៃសៅរ៍ ឬអាទិត្យតែផ្សារអាមេរិកាំង គេបិទទ្វារនៅថ្ងៃទាំង២នោះទៅវិញ ។

បើទោះជាមានចំណេះផ្សេងពីគ្នាក៏ដោយការប្រកបមុខរបរនៅទីផ្សារអាស៊ីកំពុងបំរើភ្ញៀវរបស់ខ្លួន បានយ៉ាងគាប់ចិត្តក្នុងលក្ខណៈពិសេសនៃទំនៀមទំលាប់មិនដូចគេក្នុងភាសាមិនដូចគ្នា...ប៉ុន្តែគេក៏សង្កេតឃើញដែរថា"កូនចៅនៃម្ចាស់ហាងមិនចង់បន្តរការងាររបស់ឪពុកម្តាយខ្លួនទេ បើទោះជាឪពុកម្តាយខ្លួនរកលុយបានច្រើនក៏ដោយ" ។ ករណីនេះបានចោទជាបញ្ហាមួយនៃអនាគតរបស់អាជីវកម្មជនជាតិអាស៊ីដូចជាខ្មែរ យួន លាវ ជាដើម តើនឹងរស់យូរទៅអនាគតតទៅទៀតបានប៉ុណ្ណា? នេះជាសំនួរមួយដែលពុំទាន់មានចម្លើយនៅឡើយទេ ប៉ុន្តែការសិក្សារក្នុងក្របខណ្ឌ "E For All" ទំនងជាអាចរកចម្លើយ ជូនអនាគតរបស់អាជីវកររបស់សហគមន៍អាស៊ីយើងបានជាប្រាកដ៕

Radisson Hotel & Suites
10 Independence Drive
Chelmsford, MA 01824
978 – 256 – 0800

Radisson HOTEL & SUITES CHELMSFORD - LOWELL

Come apply at the front desk today!

Positions Available for Hire:

**Banquet Houseperson:** properly set, clean and maintain all function rooms, service corridors, storerooms, and public function areas in a safe, accident-free manner. Must be able to lift up to 50 pounds. Experience in audio visual equipment is a plus!

**Banquet Server:** Set-up, service and break down assigned functions in a safe, accident-free manner. Must be able to lift up to 50 pounds.

**Restaurant Server:** Effectively promote, take and deliver food and beverage orders.

**Room Attendant:** Clean and supply all daily assigned rooms and report all damage, mechanical deficiencies, suspicious activities or theft in accordance with all housekeeping procedures and standards and safety and security rules and regulations to ensure guest satisfaction. Must be able to work on Sunday's.

Full & Part time positions available – hours vary

Benefits available for full time employees after 90 days.

# ឆ្នោត DV មករស់នៅអាមេរិកចាប់ផ្តើមទទួលការចុះឈ្មោះហើយ

**ដោយ សុខារ័ត្ន កួយ**

ឆ្នោត Diversity Visa (DV) គឺជាឆ្នោតមួយដែលរៀបចំឡើយដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកដែលទទួលខុសត្រូវដោយក្រសួងការបរទេសអាមេរិក។ ឆ្នោត DV នេះ គឺបើកជារៀងរាល់ឆ្នាំសម្រាប់បេក្ខជនទូទាំងពិភពលោក ដោយមួយឆ្នាំៗសហរដ្ឋអាមេរិកជ្រើសរើសបេក្ខជនចំនួន ៥00,000 នាក់ឱ្យមករស់នៅ និងធ្វើការជាអចិន្ត្រៃយ៍នៅសហរដ្ឋអាមេរិក។

គោលបំណងនៃការរៀបចំឆ្នោតឌូនេះឡើង គឺដើម្បីបង្កើននូវភាពចំរុះនៅក្នុងសហរដ្ឋអាមេរិក ដោយសារសហរដ្ឋអាមេរិក គឺសាងឡើងដោយជនអន្តោប្រវេសន៏ដូច្នេះឆ្នោតនេះ គឺផ្តល់ឱកាសដល់ប្រទេសដែលមានជនអន្តោប្រវេសន៏ចូលមកអាមេរិកទាប។

លោក Jason Inslee មន្ត្រីកុងស៊ុលបានឱ្យដឹងតាមរយៈកម្មវិធី Let’s Chat Facebook Live របស់ស្ថានទូតអាមេរិកកាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ ថា ចំណុចសំខាន់នៃឆ្នោត DV នេះ គឺទី១ឆ្នោតនេះមិនមានការគិតប្រាក់នោះទេ។ ទី២ គឺមិនតំរូវឱ្យមានអ្នកធានាពីសហរដ្ឋអាមេរិកនោះទេ ហើយចុងក្រោយ គឺមិនត្រូវផ្តល់ព័តិមានផ្ទាល់ខ្លួនឱ្យក្រុមហ៊ុនដែលចង់ជួយចុះឈ្មោះឱ្យលោកអ្នក។

សម្រាប់ឆ្នាំនេះ ឆ្នោត DV បានបើកឱ្យចុះឈ្មោះចាប់ពីថ្ងៃទី ៣ ខែតុលា ដល់៧ ខែវិច្ឆិការ ឆ្នាំ២០១៧នេះតទៅ។ លោកអ្នកមានរយៈពេលចំនួនមួយខែដើម្បីចុះឈ្មោះ។ ក្នុងការចុះឈ្មោះផ្សេងសំណាងលេងឆ្នោតនេះ លោកអ្នកគ្រាន់តែចូលទៅកាន់គេហទំព័រ www.lottery.state.gov ហើយធ្វើតាមការណែនាំ។




លោកអ្នកត្រូវបានជុំរុញឱ្យដាក់ពាក្យដោយខ្លួនឯង ព្រោះមានបញ្ហាជាច្រើន ដែលពលរដ្ឋខ្មែរពឹងឱ្យក្រុមហ៊ុនដាក់ពាក្យជំនួស ធ្វើឱ្យលោកអ្នកមិនមានលក្ខណៈគ្រប់គ្រាន់ទទួលបានវីសា ដូចជាក្រុមហ៊ុនទាំងនោះអាចដាក់ព័តិមានខុសចំពោះគ្រួសាររបស់លោកអ្នក, ប្រើប្រាស់ព័តិមានរបស់លោកអ្នកដើម្បីចុះឈ្មោះលេងឆ្នោតជារៀងរាល់ឆ្នាំដោយប្រើប្រាស់រូបថតចាស់។ ជានេះទៅទៀតក្រុមហ៊ុននឹងឱ្យលោកអ្នកបង់ប្រាក់រាប់ពាន់ដុល្លារនៅពេលក្រុមហ៊ុនដឹងថា លោកអ្នកជាប់ឆ្នោតរហូតដល់ពេលសម្ភាសន៏នៅស្ថានទូត។

ចំពោះលក្ខណៈនៃការចុះឈ្មោះបេក្ខជនត្រូវមានបាក់ឌុប (ជាប់ថ្នាក់ទី ១២) រឺមានបទពិសោធន៏ការងារយ៉ាងហោចណាស់ពីរឆ្នាំ, និងត្រូវបញ្ចូលព័តមានឱ្យបានត្រឹមត្រូវអំពីគ្រួសារ (ប្តី ឬប្រពន្ធ និងកូនដែលមានអាយុក្រោម ២១ ឆ្នាំ) ជាការស្រេច។

លោកអ្នកមិនចាំចាប់ Upload ឯកសារឬសញ្ញាបត្របាក់ឌុបនៅពេលចុះឈ្មោះនៅទេ។ ឯសារទាំងនោះ លោកអ្នកតំរូវឱ្យយកមកកាន់ស្ថានទូតនៅពេលធ្វើសម្ភាសន៏ ប្រសិនបើជាប់ឆ្នោតតែលោកអ្នកតំរូវឱ្យបញ្ចូលរូបថតរបស់លោកអ្នកនៅពេលចុះឈ្មោះ។ សម្រាប់ការចុះឈ្មោះ គឺលោកអ្នកចាំបាច់ត្រូវបំពេញពាក្យតាមអនឡាញជាភាសាអង្លេសដោយប្រើកុំព្យូទ័រ ឬទូរស័ព្ទស្មាតហ្វូនរបស់លោកអ្នក។ សម្រាប់រូបថត ត្រូវមានទំហំ 5X5 ដោយមានផ្ទៃខាងក្រោយពណិស។

នៅពេលដែលអ្នកចុះឈ្មោះរួចហើយ លោកអ្នកនឹងទទួលបានលេខកូនបញ្ជាក់ពិសេស (Confirmation Number) ហើយលេខកូដនេះលោកអ្នកត្រូវរក្សាទុកសម្រាប់ប្រើប្រាស់ពេលចូលទៅពិនិត្យមើលលទ្ធផល។ ដើម្បីចង់ដឹងថាតើលោកអ្នកជាប់ឆ្នោតរឺក៏អត់នោះ គឺលោកអ្នកចូលទៅកាន់គេហទំព័រដដែល www.lottery.state.gov រួចចុចទៅលើពាក្យ Check Status បន្ទាប់មកទៀតត្រូវប្រើលេខកូដបញ្ជាក់ពិសេសនោះ ដើម្បីដឹងពីលទ្ធផល នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨។

បេក្ខជនជាប់ឆ្នោត គឺត្រូវធ្វើឡើងដោយប្រព័ន្ធជ្រើសរើសដោយចៃដន្យតាមរយៈប្រព័ន្ធអ៊ុលិចត្រូនិច។ ករណីដែលលោកអ្នកត្រូវបានជ្រើសរើសជាបេក្ខជនជាប់ឆ្នោតក្រុមគ្រួសារ (ប្តី ឬប្រពន្ធ និងកូនចរបស់បេក្ខជនមានសិទ្ធិទៅកាន់សហរដ្ឋអាមេរិកជាមួយបាន។

ប្រសិនបើលោកអ្នកមិនមានឈ្មោះជាប់ជាបេក្ខជនសម្រាប់លទ្ធផលឆ្នាំនេះនោះទេ លោកអ្នកអាចដាក់ពាក្យសាជាថ្មីនៅឆ្នាំក្រោយបន្ទាប់ទៀងបានដោយគ្មានកំណត់នោះទេ។ សុំបញ្ជាក់ថា ក្នុងមួយឆ្នាំលោកអ្នកអាចចុះឈ្មោះបានតែម្តង។

ដោយសារឆ្នោតនេះគឺសម្រាប់ឆ្នាំ២០១៩ (DV 2019) ដូច្នេះការរៀបចំធ្វើសម្ភាសន៏សម្រាប់បេក្ខជនជាប់ឆ្នោត ឬអ្នកដែលត្រូវបានជ្រើសរើសនឹងចាប់ផ្តើមធ្វើនៅឆ្នាំ២០១៩។ លោកអ្នកបង់កម្រៃសេវាតែមួយគត់ប៉ុណ្ណោះសម្រាប់ដំណើរការឆ្នោតDVនេះ គឺត្រូវបានបង់នៅស្ថានទូតអាមេរិកបន្ទាប់ពីលោកអ្នកត្រូវបានជ្រើសរើសជាបេក្ខជនសម្រាប់ការសំភាសន៏ទិដ្ឋាការឆ្នោត DV។ ថ្លៃសេវាដែលត្រូវបង់សម្រាប់ឆ្នាំ ២០១៧ នេះមានចំនួន៣៣0ដុល្លារក្នុងម្នាក់។

បេក្ខជនជាប់ឆ្នោតមិនតំរូវឱ្យចេះនិយាយភាសាអង់គ្លេសនោះទេ នៅពេលមកសម្ភាសន៏នៅស្ថានទូកអាមេរិក។ ប្រសិនបើលោកអ្នកដែលធ្លាប់ដាក់ពាក្យស៊ុំវីសាទេសចរណ៏មកសហរដ្ឋអាមេរិក ហើយត្រូវបានបរិសេដដោយស្ថានទូតលោកអ្នកក៏មានសិទ្ធដាក់ពាក្យសម្រាប់ឆ្នោត DV នោះផងដែរ។ លោកអ្នកអាចចូលទៅកាន់គេហទំព័ររបស់ស្ថានទូតអាមេរិក https://kh.usembassy.gov/ ដើម្បីទទួលបានព័តិមានបន្ថែម៕



**ទស្សនៈនយោបាយ**

# ហ៊ុន សែន កំពុងស្រូតទៅក្តាប់អំណាចទាំងមូលនៅកម្ពុជា

**ដោយ ពិន សំខុន**

មិនថា មានលេសធ្វើឱ្យ"គេជឿបាន ឬមិនបាន" ក៏ដោយលោក ហ៊ុន សែន បានរឹតបន្តឹងអំណាចរបស់ខ្លួន មួយកំរិតទៀតយ៉ាងខ្ពស់ទៅរកការកាន់អំណាចតែម្នាក់ឯងដោយបញ្ជាឱ្យក្រសួងមហាផ្ទៃបញ្ជូនពាក្យបណ្តឹងឱ្យរំលាយគណបក្សសង្គ្រោះជាតិទៅតុលាការកំពូលនៅថ្ងៃ៦តុលានេះរួចហើយ។ នៅមុនឱកាសបោះឆ្នោតសាកលឆ្នាំ២០១៨ លោក ហ៊ុន សែន ត្រូវធ្វើឱ្យមានការធានាថា គណបក្សប្រជាជននឹងឈ្នះឆ្នោតជាស្វ័យប្រវត្តិ ហើយលោក ហ៊ុន សែន នៅតែកាន់អំណាចលើកម្ពុជាដដែល។

ចាប់ពីថ្ងៃទី៣ កក្កដា ថ្ងៃដែលប៉ូលិសរដ្ឋាភិបាលចូលចាប់លោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិ នៅផ្ទះរបស់លោកមក ក៏មានការរកចាប់ខ្លួនអ្នកដែលបានបញ្ចេញយោបល់ប្រឆាំងនឹងរដ្ឋអំណាចនៅគ្រប់ទីកន្លែងមានទាំងចាប់យុវជន"ហ្វេសប៊ុក" -ចាប់ខ្លួនបាតុករ-បិទកាសែតប្រឆាំងទាំងខ្មែរទាំងបរទេស-ប្រកាសបណ្តេញអង្គការមនុស្សធម៌និងសិទ្ធិមនុស្សអាមេរិកាំង-ចាប់ទាំងបាតុករដែលធ្វើការតវ៉ាពីសិទ្ធរស់នៅរបស់គេផង។ ចុងក្រោយបំផុត ហ៊ុន សែន គ្រោងចាប់សមាជិកសភាគណបក្សសង្គ្រោះជាតិច្រើនរូបទៀតនៅថ្ងៃទី៣ តុលានេះ ដោយនិយាយតាមបណ្តាញទូរទស្សន៍ថា "នឹងចាប់ខ្លួនបន្តទៅទៀតមិនមែនចាប់តែម្នាក់ហើយចប់នោះទេ!" ព័ត៌មាននេះ បានបន្តដោយដំណឹងបានធ្វើឱ្យសមាជិកសភាគណបក្សប្រឆាំងប្រមាន២០រូបទៀត បានចាកចេញពីប្រទេសទៅកាន់កន្លែងសុវត្ថិភាពស្ទើរអស់រលីងនៅសល់តែ៣-៤រូបប៉ុណ្ណោះដែលនៅចាំសម្បុក ដូចជាលោកអនុប្រធាននឹងជាតំណាងរាស្ត្រ ប៉ុល ហំ លោក សុន ឆៃ តំណាងរាស្ត្រ លោក ម៉ៅ មុនីវ៉ាន់ តំណាងរាស្ត្រ ជាដើម, ចុងបញ្ចប់ត្រូវរំលាយគណបក្សប្រឆាំងដែលជាសម្រាមក្នុងភ្នែករបស់រដ្ឋអំណាច។

ប្រតិកម្មតិចតួចពីគណបក្សសង្គ្រោះជាតិតាមរយលោកស្រីសមាជិកសភា មួរ សុខហួរ នៅលើវិទ្យុអាមេរិកាំង គឺ"ស្ថានការឥឡូវនេះវាធ្ងន់ធ្ងរបំផុត សម្រាប់កម្ពុជាមិនមែនត្រឹមតែសម្រាប់គណបក្សប្រឆាំងតែប៉ុណ្ណោះទេ គឺជាបញ្ហាសម្រាប់ប្រជាជាតិទាំងមូល -យើងមិនអាចធ្វើអ្វីបានទេ មានតែសហគមន៍អន្តរជាតិតែប៉ុណ្ណោះ ដែលមានលទ្ធភាពគាបសង្កត់លោក ហ៊ុន សែន ឱ្យត្រឡប់មករកការបោះឆ្នោត ដោយសេរីនឹងយុត្តធម៌ឱ្យបានមកវិញ"គេមិនបានឮសម្លេង លោក អេង ឆៃអៀង ឬលោក យឹម សុវណ្ណ ចេញមកតវ៉ាដូចពេលមុនៗទេ។ ពេលនេះ លោកស្រី មួ សុខហួរ កំពុងបន្តដំណើរទៅរកជួបលោកស្រីប្រធានាធិបតី អាឡឺម៉ង់ នឹងមេដឹកនាំសហគមន៍អឺរ៉ុប ដើម្បីសុំ



ប៉ូលិសចាប់ខ្លួនលោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិយប់ថ្ងៃទី ០៣ សីហា

ឱ្យជួយបញ្ចប់ស្ថានការតឹងតែងនៅកម្ពុជានេះ។

**ចំណែកប្រតិកម្មរបស់សហគមន៍បរទេសមានៈ** មានអូស្ត្រាលី -មានអង្គការសិទ្ធិមនុស្សរបស់អ.ស.ប. - មានស.រ.អា -មានសហភាពអឺរ៉ុប គេចាប់អារម្មណ៍ជាខ្លាំង ចំពោះការវិវត្តន៍ថយក្រោយរបស់កម្ពុជាទៅរករបបផ្តាច់ការនិយមនេះ -ហើយកំពុងតែរកវិធានការយ៉ាងឆាប់រហ័សទប់ស្កាត់ការវិវត្តន៍នៅកម្ពុជានេះដោយសកម្មភាពទណ្ឌកម្មសេដ្ឋកិច្ចនឹងនយោបាយដ៏តឹងតែងមកលើកម្ពុជារបស់លោក ហ៊ុន សែន មានការកាត់ជំនួយដោយចំពោះកាត់ផ្តាច់ទំនាក់ទំនងឧស្សាហកម្ម ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយកម្ពុជា។ លោក ហ៊ុន សែន ដែលបានទទួលជំនួយចិន៥០០លាន ដើម្បីផ្ទេរការគាំទ្ររបបផ្តាច់ការពីចិនប្រជាមានិត បែរជានឹងបាត់បង់ប្រាក់ចំណូលឧស្សាហកម្ម៥០០០លានដុល្លាទៅវិញ ដែលជាការគាំទ្ររបស់ប្រទេសសេរីដល់រោងចក្រទាំងឡាយនឹងដល់កម្មករដែលត្រូវការប្រាក់បៀវត្សរ៍ចាំបាច់សម្រាប់ចិញ្ចឹមជីវិតគ្រួសារ -គឺនៅពេលដែលកម្មករឥតមានការធ្វើ ហើយបាត់បង់ប្រាក់បៀវត្សរ៍របស់ខ្លួន ពេលនោះហើយដែលទណ្ឌកម្មពិតប្រាកដនឹងមកដល់លើរដ្ឋបាលលោក ហ៊ុន សែន។ ចំណែកឯទណ្ឌកម្មនយោបាយវិញ សហគមន៍អន្តរជាតិបានគ្រោងថា "បើគ្មានគណបក្សសង្គ្រោះជាតិចូលរួមទេនោះ ការបោះឆ្នោតនឹងគ្មានភាពយុត្តិធម៌មិនអាចឱ្យគេគាំទ្របានទេ"។ គេនៅចាំបានថា "កាលពីឆ្នាំ១៩៩៨ អ.ស.ប. បានដកអាសនៈកម្ពុជាចេញពីការទទួលស្គាល់, ដោយលោក ហ៊ុន សែន បានដាក់រដ្ឋាភិបាលបន្ទុបគឺលោក អ៊ឹង ហួត ជានាយករដ្ឋមន្ត្រីជំនួសទ្រង់ រណឫទ្ធិ ជានាយករដ្ឋមន្ត្រីជាប់ឆ្នោត" ពេលនោះ អ៊ឹង ហួត បានត្រឹមតែអង្គុយត្រឹមតែអសនៈអ្នកសង្កេតការនៅអ.ស.ប. តែប៉ុណ្ណោះ, មិនត្រឹមតែមិនទទួលស្គាល់ទេ ថែមទាំងគេកាត់ជំនួយទៅកម្ពុជាអស់រលីងទៅទៀត

-ក្រោយមកយើងក៏បានឃើញលោក ហ៊ុន សែន បានបន្ទន់ឥរិយាបទយ៉ាងណាទេ? ដើម្បីឱ្យបានតែនៅកាន់អំណាចបន្តទៅទៀត...ដើម្បីពង្រឹងមកវិញម្តងទៀតនៅពេលនេះ។ រីឯទ្រង់នរោត្តម រណឫទ្ធិ អតីតនាយករដ្ឋមន្ត្រីទី១ កន្លះអាណត្តិវិញពុំបានចងចាំមេរៀននៃអតីតកាលទេ ស្តេចវិញ្ញាណខ្លីអង្គនេះ បានប្តឹងឱ្យរំលាយ-សម្លាប់គណបក្សសង្គ្រោះជាតិ ដូចដែលលោកបានធ្វើជាមួយមិត្តរួមអារ៉ុចច្រើនរយនាក់របស់គណបក្សហ៊្វុនស៊ិនប៉ិចរបស់លោក កាលពីឆ្នាំ១៩៩៧នោះដែរ។

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ជាមន្ត្រីជាន់ខ្ពស់ខាងគណបក្សសង្គ្រោះជាតិ ដែលកំពុងធ្វើទស្សនកិច្ចនៅឡូវែល ព្រះអង្គទើបនឹងបានជួបលោក សម រង្ស៊ី នឹងតំណាងរាស្ត្រ ជូឡុង សូមួរ៉ា ជាភរិយានៅទីក្រុងប៉ារីស, នៅពេលសួរថា "តើនៅពេលដឹងថា គណបក្សសង្គ្រោះជាតិនឹងត្រូវរំលាយភ្លាមនោះ តើមានប្រតិកម្មយ៉ាងណា?" ព្រះអង្គតបថា"លោក រង្ស៊ី មិនបានធ្វើអត្ថាធិប្បាយពីការរំលាយគណបក្សនេះទេ លោករវល់នឹងការបង្កើតសមាគមថ្មីរបស់លោក ដើម្បីបង្កលទ្ធិប្រជាធិបតេយ្យនៅកម្ពុជារបស់លោក..." ព្រះអង្គបន្តថា "លោក រង្ស៊ី គួរតែជួបសមាជិកសភាទាំងអស់ ដែលបានចាកចេញពីកម្ពុជាដោយការគម្រាមកំហែង ដើម្បីពិចារណាលើស្ថានការថ្មីដែលទើបនឹងមកដល់"។

លោកតំណាងរាស្ត្រ យឹម សុវណ្ណ បាន

**តទៅទំព័រទី ២០**



# មេធាវីធីមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

## Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

រឿងប្រលោមលោក

# រឿង ចៅពិន



**នាអំឡុងឆ្នាំ១៩៥០-៦០ តើមានអ្វីកើតឡើងនៅក្នុងជីវភាពគ្រួសារខ្មែរ!**

ដោយ ខ្មែរផុសស.រ.អា

**តពីលេខមុន**

ពេលវេលាក៏បានកន្លងទៅជាង១ខែទៀត យ៉ាងឆាប់រហ័ស ចៅពិន ក៏បាននៅសាំនឹងជីវភាពវត្តទៅហើយដែរ...ប៉ុន្តែនៅចុងសប្តាហ៍នៃខែកញ្ញាឆ្នាំ១៩៥៣នេះ ចៅពិន មិនបាននៅវត្តទៀតទេ ឪពុកម្តាយគេក៏មកថ្វាយបង្គំលោកគ្រូយកកូនទៅវិញ ពីព្រោះដល់ពេលចូលរៀនហើយ ចៅថាច នៅអាយុកន្លះឆ្នាំទៀត ទើបដល់អាយុចូលរៀនបាន, ពេលលាគ្នាក៏មកដល់...

-អាថាច អញលាឯងទៅសិនហើយ! បើឯងទៅបន្ទាយវិញ ទៅរកអញផងណា! ចៅពិន ដើរទៅជិតកាន់ដៃចៅថាច

-អុឺ ! ទាំងរលីងរលោងទឹកភ្នែក មិនអាចនិយាយអ្វីឱ្យលើសពីនេះបាន មិត្តភាពបានចងកុមារទាំងពីរនាក់នេះបានជ្រាលជ្រៅ នាគ្រាក្រច្រើនណាស់ទៅហើយ ការបែកគ្នាទៅវិញនា ពេលនេះ មិនដឹងជាពេលណាបានជួបគ្នាវិញទេ... បន្ទាប់ពីថ្វាយបង្គំលាលោកគ្រូរួចហើយ លោកកុម៉ង់ដង់មុំាង បាននាំកូន ក្នុងរថយន្តហ្ស៊ីពទាហ៊ានចេញទៅបាត់ តែ ចៅថាច មិនអាចនៅសម្លឹងការចេញដំណើរនេះបានទេ ទំនងជាតឹងទ្រូងខ្លាំងណាស់ហើយ ពុំមាននរណាលួងចិត្តខ្លួនឡើយ... ផ្ទុយគ្នានឹង ចៅថាច ចៅពិន បានអង្គុយយ៉ាងស្ងៀមស្ងាត់ តែបានម្តាយនៅក្បែរគ្រាន់ជាការលួងចិត្តដែលកំពុងកំសត់បានគ្រាន់បើបន្តិចដែរ ។

មកដល់បន្ទាយវិញ ទើប ចៅពិន ដឹងថាឪពុកខ្លួននឹងផ្លាស់ចេញទៅកាន់ទីក្រុងភ្នំពេញនៅពេលឆាប់ៗខាងមុខហើយ តែមុននឹងចេញដំណើរទៅ ម្តាយ ចៅពិន បានយកពេលមួយមកប្រាប់កូនថា:

-នៅបន្តិចទៀត ប៉ា-ម៉ាក់ នឹងបងស្រីកូនបងពុំត្រូវចេញដំណើរទៅភ្នំពេញហើយ តែកូនត្រូវនៅកំពង់ស្ពឺនេះជាមួយអ្នកបងស៊ុននី នៅរៀនទីនេះជាមួយអ្នកបងឮទេ?

-បាទម៉ាក់ ! ចៅពិនឆ្លើយរាងភ្ញាក់ផ្អើល តែហាក់ដូចជាមិនមានអារម្មណ៍លំបាកចិត្តមិនសូវខ្វល់ពីការចេញដំណើររបស់ឪពុកម្តាយទៅចោលខ្លួនប៉ុន្មានទេ ទំនងជាដោយសារធ្លាប់បែកពីឪពុកម្តាយខ្លួននោះ យូរខែបន្តិចហើយ បែកថែមទៀតក៏មិនអីដែរ ហើយទៅនៅជាមួយបងស្រីខ្លួន ក៏មិនមែនជាអ្នកក្រៅដែរ...

-ម្តាយ ចៅពិន ក៏បន្តថា ចាំម៉ាក់ដេរខោអាវថ្មីៗឱ្យកូនបានទៅរៀន ចូរកូនខំរៀនណាកូន!

លោកស្រី កុម្មង់ដង់ បានរៀនដេរខ្លះៗពីម្តាយកាលពីនៅកោះសូទីន ខែត្រកំពង់ចាម ដែលជាស្រុកកំណើតមុនពេលលោកស្រីរៀបការជាមួយលោក មុំាង ពេលនោះជាសិស្សសាលានាយទាហ៊ាន ដែលបានចូលមកបំរើគ្រួសារលោក



មេស្រុកក្បាលកោះសូទិន ឈ្មោះស៊ឹម ជាច្រើនឆ្នាំ មុនគេនឹងលោកស៊ឹម លើកកូនស្រីឱ្យ តាមទំនៀមទំលាប់នៃប្រពៃណីខ្មែរ ។ កាលពីពេលដែលលោកកុម្មងដង់មុំាងផ្លាស់ចេញពីកំពង់ចាម លោកបានទិញម៉ាស៊ីនដេរម៉ាង"សាំងហ្សេ - Singer" ជាម៉ាកដែរល្បីថា ល្អស្រួលប្រើ នឹងវិទ្យុទំនើបមួយគ្រឿងសម្រាប់ស្តាប់ព័ត៌មាននឹងស្តាប់ភ្លេងនានា...លោកស្រី មុំាង គិតថានឹងឱ្យវត្ថុដ៏មានតម្លៃទាំង២នោះ ទៅឱ្យកូនស្រីបងបន្តទៅទៀត នៅពេលផ្លាស់ចេញទៅភ្នំពេញលើកនេះ។

ចៅពិន នៅជាមួយម្តាយឪពុកមិនយូប៉ុន្មានមួយសប្តាហ៍ក្រោយមក នាថ្ងៃអាទិត្យ លោកកុម៉ង់ដង់ មុំាង លោកស្រីបងស្រី យ៉ាស៊ុន នឹងចៅពិន ក៏ជិះឡាន "ហ្ស៊ីបទាហ៊ានចេញមកផ្ទះបងស៊ុននី នៅកណ្តាលក្រុង ។ បង ស៊ុននី មានផ្ទះថ្មបីល្វែងមាន២ជាន់ ដែលជាផ្ទះថ្មដំបូងបង្អស់នាទីក្រុងកំពង់ស្ពឺ ស្ថិតនៅជាប់អូរឬស្សីបែរមុខទៅទិសខាងជើងមើលទៅរការធំដែលឪពុកទើបនឹងសង់ឱ្យ ។ បងវ៉ាន់ថន ជាបងថ្លៃធ្វើការនៅក្រសួងសុរិយោដីរវល់ខ្លាំងណាស់ដោយក្រុងកំពង់ស្ពឺទាំងមូល កំពុងផ្លាស់ប្តូរពីហាងលក់ដូរនៅជាប់មាត់ផ្លូវត្រូវប្តូរពីហាងឈើដែលកាន់តែរខេករខាកទៅហើយ ឱ្យទៅជាហាងផ្ទះថ្មវិញទាំងអស់, បង វ៉ាន់ថន ដែលជាអ្នកឯកទេសគូរប្លង់ផ្ទះតែម្នាក់គត់នៅប្រចាំក្រុងកំពង់ស្ពឺទាំងមូលបានត្រូវទទួលភារៈកិច្ចបន្តបន្ទាប់ឱ្យធ្វើប្លង់ផ្ទះជូនពាណិជ្ជករក្រៅម៉ោងធ្វើការតាំងតែពីជិតមួយឆ្នាំមកហើយ...តែទាំងអស់គ្នាសប្បាយចិត្តណាស់ រាប់ទាំង អាធា ជាកូនស្រីរបស់អ្នកបង ស៊ុននី ផង ក៏រីករាយណាស់ នឹងទទួលម្តាយឪពុកក្មេករួមទាំងប្អូនៗធ្វើឱ្យគ្រួសារទាំងមូលបានជួបជុំគ្នា គួរឱ្យរីករាយជាទីបំផុត។

លើសពីនេះទៅទៀត ចៅប៊ុនដែលទៅរស់នៅកំពង់ចាម នាសាលាកុមារយោធិន្ទតាំងតែពីឆ្នាំមុនក៏មកដល់កំពង់ស្ពឺ នាថ្ងៃនេះដែរ ដោយសារតែពេលវិស្សមកាលសាលាអនុញ្ញាតឱ្យសិស្សចេញមកជួបក្រុមគ្រួសារបាន១ខែកន្លះ ហើយនៅសល់ពេលវិស្សមកាល១ខែកន្លះទៀត ជាពេលសម្រាប់ត្រឡប់ទៅហាត់វិជ្ជាកងទ័ពនៅក្នុងបន្ទាយវិញ។

ចៅប៊ុនពេលនេះអាយុបាន១១ឆ្នាំហើយ មកដល់ផ្ទះភ្លាមទាំងអស់គ្នាភ្ញាក់ផ្អើលណាស់ ដោយមិនដែលឃើញកូនក្មេងស្លៀកឯកសណ្ឋានជាទាហ៊ានខោអាវគគី ស្បែកជើងស្រោមជើងទាហ៊ាន ពាក់បេរ៉េក្រហម នៅលើស្មាមានពាក់ "បារែត"ដាក់អក្សរ"AET"ចៅពិនរីករាយនឹងពន្យល់ថា នេះជាពាក្យបារាំងបានន័យថា "Ecole des Enfants de Troupe"។ ចៅប៊ុន ចេញដំណើរដោយជិះឡានឈ្នួលពីផ្សារកំពង់ចាម តាំងពីម៉ោង៣ទៀបភ្លឺ មុនព្រលឹមស្រាង១ មកដល់ក្រុងភ្នំពេញប្រមាណម៉ោង៩ព្រឹក ហើយឡើងរថយន្តឈ្នួលមួយទៀតបន្តដំណើរមកឈប់នៅផ្សារកំពង់ស្ពឺ។ មកដល់ផ្ទះនាថ្ងៃត្រង់ជម្រាបសួរប៉ាម៉ាក់ អ្នកបងស៊ុននី បងពុំ បងវ៉ាន់ថន រីករាយនឹងឃើញបងប្អូននៅជុំគ្នាថ្ងៃនេះណាស់, ចំណែកចៅពិនវិញ តាមនិយាយរកបងប្រុសមិនឈប់ ពីព្រោះចង់ដឹងណាស់ពីជីវិតបងនៅឯកំពង់ចាមតែម្នាក់ឯង ។

ផ្សារកំពុងចាមតាំងពីម៉ោង៣ទៀបភ្លឺ មុនព្រលឹមស្រាង១មកដល់ក្រុងភ្នំពេញប្រមាណម៉ោង៩ព្រឹក ហើយឡើងរថយន្តឈ្នួលមួយទៀតបន្តដំណើរមកឈប់នៅផ្សារកំពុងស្ពឺ។ មកដល់ផ្ទះនាថ្ងៃត្រង់ ជម្រាបសួរប៉ាម៉ាក់ អ្នកបងស៊ុននី បងពុំ បងវ៉ាន់ថន រីករាយនឹងឃើញបងប្អូននៅជុំគ្នាថ្ងៃនេះណាស់, ចំណែក ចៅពិន វិញ តាមនិយាយរកបងប្រុសមិនឈប់ ពីព្រោះចង់ដឹងណាស់ពីជីវិតបងនៅឯកំពុងចាមតែម្នាក់ឯង ។

ចៅប៊ុនបានយកពេលនិយាយប្រាប់ប្អូននឹងគ្រួសារដែលនៅជុំវិញរង់ចាំស្តាប់នៅជុំវិញក្តាង្សឿកណ្តាលផ្ទះនោះថា: ខ្ញុំបានទៅចូលរៀននៅសាលារៀនធំទូលាយមួយដែលមានសុទ្ធតែកូនទាហ៊ាន៣០០នាក់ មានតូចមានធំខ្ញុំមានអាយុតិចជាងគេហើយតូចជាងគេ -មាននាយទាហ៊ានជាអ្នកបញ្ជានឹងមើលពួកយើងក្មេងៗឱ្យហាត់ជាទាហ៊ាន, លោកកុម៉ង់ដង់ខ្ញុំពាក់សក្តិ២បញ្ជាទាហ៊ានធំ៧១"សិចស្យុង"- ពួកខ្ញុំស្លៀកពាក់ជាទាហ៊ានទាំងអស់គ្នា ដែលគេបើកឱ្យដូចដូចគ្នា - រាល់ខែ "អូដេ" គេបើកប្រាក់ខែឱ្យខ្ញុំ១០០រៀលសម្រាប់ទិញនុំញាំ ហើយគេសន្សំទុកឱ្យ១០០រៀលទៀត -ពួកយើងតូចៗ គេឱ្យដេកនៅ "ស្ទូម"មួយវែង លើ"បាប្លង់"គ្នា៣០នាក់ គេឱ្យកន្ទេល១ ភួយ១ មុង១ម្នាក់ -ព្រឹកឡើងគេផ្លុំត្រែដាស់យើងនៅម៉ោង៥កន្លះព្រឹកឱ្យយើងហាត់ប្រាណ រួចទៅញុំាបបរ រួចទៅងូតទឹកស្លៀកពាក់ជា"វែក្លឺម៉ង់"រួចទាហ៊ានគេផ្លុំត្រែ"រ៉ាសមប្លឺម៉ង"មាន"សែពឌុយស្ទូ"គេហៅលេខ, គេលែងហៅឈ្មោះខ្ញុំហើយ គេហៅលេខខ្ញុំថា "២៩៤" ជាភាសាបារាំង ខ្ញុំត្រូវឆ្លើយតបថា "ប្រេស្ហង់" (ចៅប៊ុនដម្លើងសម្លេងស្រែកដូចដែលខ្លួនធ្វើរាល់ថ្ងៃនៅសាលា ធ្វើឱ្យទាំងអស់គ្នាភ្ញាក់ ហើយសើចគិលឡើង...) គ្រប់ចំនួនហើយ រាយការទៅ"ស៊ែហ្សង់"រួចនាំគ្នាដើរទៅសាលារៀន..."។ ចៅពិនទឹកឆ្ងល់ហើយសួរទៅបងខ្លួនថា:"បើគ្នាច្រើនអ៊ីចឹង ទៅងូតទឹកយ៉ាងម៉េចទៅ?" បងប្រុសឆ្លើយថា"គេមាន"បាសាំង"ធំវែងមួយមានទឹកពេញយើងមានផ្តិលមួយម្នាក់ច្រាសដុសធ្មេញមួយសាប៊ូ១ដុំម្នាក់ ទៅងូតទឹកជុំគ្នា -យើងងូតទឹកស្រាតទាំងអស់គ្នា..." ចៅពិន អាយុ៧ឆ្នាំហើយ ចាប់ផ្តើមយល់ពិការខ្មាសអៀន ក៏ឧទានថា "ធំៗហើយ ស្រាតទាំងអស់គ្នា...ហាំ!" ហើយក៏រត់ចេញទៅ...ដោយអៀនជុំនួសគេ...ទាំងអស់គ្នាសើចគិលឡើងម្តងទៀត ហើយក៏បំបែកជួរទាំង

**តទៅលេខក្រោយ**

# ដំណឹងរើសបុគ្គលិក

- ត្រូវការអ្នកជួយនៅផ្ទះបាយ
- បោសសំអាតផ្ទះឱ្យបានស្អាត និងរៀបចំឱ្យមានរបៀបរាបរយ
- ធ្វើការពី ២ ទៅ ៣ ពេល ក្នុងមួយសប្តាហ៍- ៤ ទៅ ៦ ម៉ោងក្នុងមួយថ្ងៃ
- ម៉ោងធ្វើការផ្លាស់ប្តូរបាន

# សេងហាងដូណាត់នៅរដ្ឋ Kentucky

ហាងបើកលក់បាន១ឆ្នាំកន្លះ, មានចំណូលរាល់ខែ។

ហាងធំទូលាយ, នៅចំផ្លូវធំ និងមាន Drive thru.

សម្រាប់អ្នកមិនទាន់ចេះធ្វើនំ, យើងខ្ញុំនឹងបង្រៀនមួយចេះ ។

ព័ត៌មានលំអិតសូមទូរស័ព្ទមកកាន់ **(270) 484-6397**




# MARCOTTE LAW FIRM

## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- ច្បាប់ធានារ៉ាប់រង
- សំណងបុគ្គល
- ការរំលោភបទព្រហ្មទណ្ឌ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បំណុលអចលទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

www.marcottelawfirm.com

# ដំណឹងរកបុគ្គលិកចែកផ្សាយ

ខ្មែរផុសស.រ.អា.ត្រូវការរកបុគ្គលិកសម្រាប់ចែកផ្សាយកាសែតនៅក្នុងតំបន់មានឡូវែល - លីន រីវ៉េ - ក្រេងស្តុន រ៉ូដអាយឡិន ។ កាសែតចែក២ដងក្នុង១ខែ ។ បេក្ខជនត្រូវមានប័ណ្ណបើកបរ នឹងធ្លាប់ស្គាល់តំបន់ច្បាស់លាស់ ។ សូមទាក់ទងមកទីស្នាក់ការយើង នៅលេខ **978 - 677 7163** ឬទាក់ទងមក **សូបិន 978-656 8141**

ខ្មែរផុស ស.រ.អ
KhmerPost USA
*Cambodian American Biweekly Newspaper*

Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS

Contact us for the Advertising Opportunity!

978-677-7163 | http:/khmerpost.us

តមកពីទំព័រទី ១៦

## ហ៊ុន សែន កំពុងស្រូតក្តាប់អំណាច...

និយាយប្រាប់ប្រជាពលរដ្ឋនៅឡូវែលកាលពី២ សប្តាហ៍មុននេះថា"បំណងរំលាយគណបក្សសង្គ្រោះជាតិ វាមានផលវិបាកធ្ងន់ធ្ងរណាស់ គឺសមាជិកសភាជាតិជិតពាក់កណ្តាលមកពីសង្គ្រោះជាតិត្រូវរលាយ -សមាជិកឃុំសង្កាត់ជាង៥ពាន់នាក់ ក៏ត្រូវរលាយ -សមាជិក៤រូប នៅគ.ជ.ប. ក៏ត្រូវរលាយ បើទោះជាការពារដោយរដ្ឋធម្មនុញ្ញក៏ដោយ -ជាពិសេសគណបក្សសង្គ្រោះជាតិជាតំណាងឱ្យប្រជាពលរដ្ឋជាង៣លាននាក់ក្នុងប្រទេស តើប្រទេសកម្ពុជានឹងក្លាយទៅជាអ្វី? លោក យឹម សុវណ្ណ បានសន្និដ្ឋានថា"មិនអាចធ្វើទៅរួចទេ!" តែលោក ហ៊ុន សែន មិនបានខ្វល់ពីភាពស្របច្បាប់នៃស្ថាប័នប្រទេសប្រជាធិបតេយ្យនោះទេ។

នៅពេលដែលរំលឹកពីការចាប់នាវាដែលមានទង់ជាតិខ្មែរ ដឹករត់ពន្ធអាវុធ ""រ៉ុកែក"៣ម៉ឺនគ្រាប់ ព្រះអង្គមានបន្ទូលថា "ជារឿងចាស់ដែលកើតឡើងពីខែមេសាមកម្ល៉េះ ស្រាប់តែវាផុសឡើងចំពេលនេះ នៅលើទំព័រកាសែត"វ៉ាស៊ីនតោនផូស" វាប្រាកដជាមិនមែនជារឿងចៃដន្យទេ វានឹងធ្វើឱ្យមានការស៊ើបអង្កេតរបស់"ស៊ីអាយអេ ឬក៏អាំងទែប៉ូល"ធំៗ យ៉ាងគគ្រឹកគគ្រេងមិនថា ប៉ះលើក្រុមលោក ហ៊ុន ម៉ាណែត ឬក្រុម ជូស្នេហ៍ទេ អ្នកនោះនឹងត្រូវប៉ូលិសអន្តរជាតិតាមចាប់ខ្លួនជាមិនខាន។

ដូចដែលយើងធ្វើអត្ថាធិប្បាយពីមុនមកដែរ ការភ័យស្លន់ស្លោខ្លាចចាញ់របស់លោក ហ៊ុន សែន ពេលនេះ គឺលោកគិតតែពីចង់ឈ្នះពុំបានធ្វើឱ្យលោកគិតថា"នឹងមានពេលចាញ់ផងទេ" ដូច្នេះលោកត្រូវ"ចាក់ផុក"យកតែពីខាងឈ្នះ។ មតិកាន់តែច្រើន បានឱ្យយោបល់ថា "លោក ហ៊ុន សែន កំពុងតែធ្វើឱ្យមានការគ្រោះថ្នាក់ដល់ក្រុមគ្រួសារគាត់ ព្រមទាំងដល់មិត្តភ័ក្រ្តនៃគណបក្សប្រជាជន រួមអាវុធរបស់គាត់ថែមទៀត នៅពេលដែលគណបក្សប្រជាជនត្រូវរងការទណ្ឌកម្មរបស់សហប្រជាជាតិផង -ពីការសងសឹករបស់ប្រ-ជាជនខ្មែរក្រីក្រផង នឹងពីការចាញ់ឆ្នោតផង"។ នយោបាយរបស់ ហ៊ុន សែន កំពុងបង្កសត្រូវជុំវិញខ្លួនមានរាប់ទាំងគ្នាគាត់ផងដែរ... ទ្រង់ធម្មិកោធ្លាប់មានបន្ទូលថា "កាលពីលោក ហ៊ុន សែន ឈ្នះ៩៣ អាសនៈនៅសភាគាត់យកពេលជាច្រើនសម្រាប់កំចាត់គ្នាគាត់មានតាំងពីកំចាត់លោក ជា ស៊ីម ជាប្រធានគណបក្ស, លោក កែ គឹមយ៉ាន អគ្គមេបញ្ជាការកងទ័ពជាតិ, ដាក់មនុស្សរបស់លោកទៅអែបនឹងនឹងលោក ស ខេង... ។ល។ បញ្ចេញកងប្រដាប់អាវុធច្រើនដង គឺដើម្បីគម្រាមគ្នាគាត់កុំឱ្យហ៊ានងើបតតាំងនឹងគាត់ដូចជាថ្មីៗនេះ បញ្ចេញទ័ពទាំងប្រទេសទៅទប់ទល់នឹងការឈ្លៀនពានរបស់ទ័ពឡាវប្រមាណ ៤០នាក់ប៉ុណ្ណោះជាដើម។ នៅពេលណាមួយដែលសម្បត្តិរបស់គាត់ត្រូវបានគេ"បង្កក"បាន, កងទ័ពលក់ជីវិតរបស់គាត់ក៏ប្រើលែងកើត, មិត្តរួមអាវុធក៏គេមិននៅជិត, ពេលនោះនៅសល់តែមនុស្សដែលមានវាសនាដូចគ្នាតែម្នាក់ដែលនៅជិតគាត់ គឺ សាដាម ហ៊ូសែន គ្រាន់សាទុក្ខដាក់គ្នាបាន ៕



លោក យឹម សុវណ្ណ



ព្រះអង្គម្ចាស់ ធម្មិកោ



អាវុធនឹងកាំជ្រួចរាប់ម៉ឺនតោនចាប់បាននៅលើកប៉ាល់ដែលមានទង់ជាតិខ្មែរ នៅប្រទេសអ៊ីហ្សិប


The State of Rhode Island and Providence Plantations
Department of Administration
Division of Human Resources, Office of Classification & Examination

**RECRUITMENT ANNOUNCEMENT**

### JUVENILE PROGRAM WORKER

**Salary Range from $43,228 – $49,062* (Pay Grade 22A)**

To provide for the custody, supervision and security of youth detained in the Rhode Island Training School for Youths including assisting in the rehabilitation, education, treatment, care and control of these residents and to do related work as required.

***EDUCATION AND EXPERIENCE:***

Education: Such as may have been gained through: Possession of an Associate's Degree with preferred specialization in a Behavioral Science, or in Social Work; and
Experience: Such as may have gained through: employment in a responsible position in a clinical or correctional treatment facility.

***Application Process:*** *Qualified applicants must pass a BCI/NCIC, Child Protective Screen, Drug Screen, Interview Boards and Psychological Screen.*

All qualified applicants must complete a 6-8 week Pre-Service Training Academy

APPLICATION PERIOD: All resumes must be received by November 10, 2017

Interested parties should submit resume to the address listed below.

Department of Children, Youth and Families
Attn: Janet Mahoney
101 Friendship Street
Providence, RI 02903

Open hour and informational sessions will be at the following locations, dates, and times:

*Youth Transition Center – 790 Broad Street, Providence, RI 02905 – Tuesday, October 24, 2017, 4:00-6:00pm
*Youth Transition Center – 242 Dexter Street, Pawtucket, RI 02860 – Thursday, October 26, 2017, 1:00-3:00pm
*Rhode Island Training School – Youth Development Center – 57 Power Road, Cranston, RI – Tuesday, October 17, 2017, 1:00-3:00pm

**SPECIAL REQUIREMENTS:**

At the time of appointment must be capable of performing (with or without reasonable accommodation) the essential duties as evidenced by a physician's certificate and must continue to be qualified to perform assigned duties through employment. Must have successfully completed and graduated from Department of Children, Youth and Families Juvenile Correction Pre-Service Training Program. In accordance with RIGL 42-28.3-1 no person shall be appointed temporary, probationary, or permanent until they shall have been evaluated and tested by a certified psychologist and receive a
satisfactory rating which shall be in writing

After graduating from Pre-Service Training Academy
candidates may be placed on a hiring list and offered employment upon positions becoming available.

**AN EQUAL OPPORTUNITY/AFFIRMATIVE ACTION AND DIVERSITY EMPLOYER.**
Women and minorities are encouraged to apply.
Any individual with a disability who requires assistance to effectively participate in the application process should contact the Department of Administration at the above number prior to the close of the application period.

*Wages subject to union contract*



KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Contributing Writers:**
Richard Howe Jr,
ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Tw tter KhmerpostUSA

សហគមន៍ - ការប្តេជ្ញាចិត្ត-សេវាកម្ម

សូមបោះឆ្នោតអោយ
JOHN J. LEAHY
សំរាប់ក្រុមប្រឹក្សាក្រុង
ថ្ងៃអង្គារ៍ ទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧

មានលេខរៀង#11
នៃបញ្ជីបេក្ខជនឈរឈ្មោះ
បោះឆ្នោតលោកជាមនុស្សដែ
លសកម្មក្នុង
សហគមន៍,ចេះយកចិត្តទុក
ដាក់ចំពោះពលរដ្ឋនឹងមាន
ចំណេះដឹងដើម្បីដោះស្រាយ
បញ្ហាបានត្រឹមត្រូវ។
លោកដឹកនាំសហគ្រាសឯកជ
នទៅកាន់រដ្ឋាភិបាល។



ឧបត្ថម្ភគណកម្មការសម្រាប់បោះឆ្នោត អោយលោក John J. Leahy


## តមកទំព័រទី ០៧ ឱកាសបណ្តុះបណ្តាលផ្នែកផលិតកម្ម...

ម៉ោងរួមជាមួយនឹងអត្ថប្រយោជន៍ផ្សេងៗទៀត។

លោក Nancy Gagnon ជាអ្នកគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលមុខរបរឡូវែលបាននិយាយថា "ការពិតអាជីពធ្វើការនៅក្នុងការផលិតតាមបែបទំនើបនៅក្នុងនិងជុំវិញទីក្រុងឡូវែល គឺកំពុងតែមានតម្រូវការខ្ពស់នាពេលបច្ចុប្បន្ននេះ ដែលក្រុមហ៊ុនជាច្រើន គឺតែងតែជួបប្រទះនឹងកង្វះអ្នកបំរើការងារ" ។

យោងទៅតាមការវិភាគកាលពីឆ្នាំមុននៅតំបន់ Greater Lowell មានឱកាសការងារចំនួនជាង៥៨០នាក់សម្រាប់អ្នកបច្ចេកទេស និងវិស្វករ និង១៩០មុខតំណែងដែលត្រូវការអ្នកដែលមានកម្រិតជំនាញដំបូងក្នុងការផលិត នៅតាមក្រុមហ៊ុនផលិតនានាជាច្រើន។ ក្រុមហ៊ុនទាំងនេះរួមមានក្រុមហ៊ុនផលិតឱសថ្ស ថ្នាំពេទ្យ, គ្រឿងបរិក្ខាពេទ្យ, គ្រឿងប្រើប្រើសក្នុងផ្ទះបាយ, ឧបករណ៍សម្រាប់ប្រើនឹងដៃ, ឧបករណ៍ Semiconductor, ឧបករណ៍អេឡិចត្រូនិច និងគ្រឿងបង្គុំអេឡិចត្រូនិក។

ក្រុមហ៊ុនផលិតនៅទូទាំងតំបន់ឡូវែលបានស្រូបកំលាំងពលកម្មប្រមាណ១៦,០០០នាក់ដែលមានមុខតំណែងពាក់ព័ន្ធនឹងការផលិតកម្មផ្សេងៗជាច្រើន។ ក្រុមហ៊ុនមួយចំនួនក្នុងចំណោមក្រុមហ៊ុនទាំងនេះរួមមានZell Medical, MA / COM, Nova Biomedical, Four in One, PaceIndustry, Thermo Fisher, Raytheon, Enterprise, Lantheus Medical, Analog Devices, Cabot Corporation nigUnited Technologies ។

លក្ខ័ណដែលអាចចុះឈ្មោះក្នុងកម្មវិធីនេះ បេក្ខជនត្រូវតែមានអាយុចន្លោះពី១៨- ២៩ឆ្នាំ, មានសញ្ញាបត្រ HS, GED ឬ HiSET; ពលរដ្ឋ ស្នាក់នៅអចិន្ត្រៃយ៍ និងមានសិទ្ធិស្របច្បាប់ក្នុងការធ្វើការនៅសហរដ្ឋអាមេរិក, ហើយត្រូវប្រឡងតេស្តកម្រិតថ្នាក់ទី៨ ផ្នែកគណិតវិទ្យា និងការអានជាភាសាអង់គ្លេសឬមានជំនាញភាសាអង់គ្លេស និងមានបទពិសោធន៏ការងារខាងលើ។

ទាក់ទងមកកាន់ Nancy Gagnon តាមរយៈលេខទូរស័ព្ទ ៩៧៨-៨០៥-៤៧៣៤ ឬ nancy.Gagnon@cclowell.org ដើម្បីចុះឈ្មោះសម្រាប់ចូលរៀននៅថ្ងៃទី៣០ ខែតុលាខាងមុខ៕


បង់ថ្លៃបូកផ្សំ $0

ណាត់ជួបវេជ្ជបណ្ឌិត $0 ការមើលថែធ្មេញ $0 សេវាចក្ខុវិញ្ញាណ $0

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅ ដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth រួមបញ្ចូលទាំងការធានាលើថ្នាំតាមវេជ្ជបញ្ជា Part D បូកផ្សំនឹងអត្ថប្រយោជន៍ច្រើនទៀតដូចជា៖

- ប័ណ្ណ OTC សម្រាប់ទិញថ្នាំ និងផលិតផលិតផលទាក់ទងនឹងសុខភាពជាក់លាក់ដែលមិនចាំបាច់វេជ្ជបញ្ជា *(រហូតដល់ $300 ក្នុងមួយឆ្នាំ ឬ $75 ក្នុងមួយត្រីមាស)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំគិលានុបដ្ឋាកដែលសម្របសម្រួលការមើលថែទាំរបស់អ្នកដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក។

ទាំងអស់ក្នុងផែនការងាយស្រួលតែមួយពី **Senior Whole Health**។

SWH SENIOR WHOLE HEALTH®
Simple. Secure. Independent.




ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare Part A និង/ឬ Part B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
(លេខឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងបើកពីម៉ោង 8 ព្រឹកដល់ 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវបានអនុវត្ត និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។*
*ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY/TDD: 711).*
*ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY/TDD: 711).*

សុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា (HMO SNP) និងសុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយសហធនម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ: EOHHS។ ការចុះឈ្មោះធ្វើឡើងតាមការស្ម័គ្រចិត្ត និងអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។ ព័ត៌មាននេះពុំមែនជាការពិពណ៌នាពេញលេញនៃអត្ថប្រយោជន៍ឡើយ។ ទាក់ទងផែនការនេះសម្រាប់ព័ត៌មានបន្ថែម។ អាចនឹងមានការដាក់កម្រិត ការបង់ថ្លៃបូកផ្សំ និងការកំហិត។ អត្ថប្រយោជន៍អាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ សហចំណាយអាចប្រែប្រួលអាស្រ័យលើកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទំនាក់ទំនងទៅផែនការសម្រាប់ព័ត៌មានលម្អិតបន្ថែម។ ផែនការនេះអាចប្រើបានសម្រាប់អ្នកអាយុ 65 ឆ្នាំឡើងទៅ ដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋ និង Medicare។ H2224_2016_138kh Accepted 11/25/2016

GREATER LOWELL
CHAMBER OF COMMERCE

Nashoba Valley
The Chamber that opens doors.

# អញ្ជើញចូលរួមដោយសេរី

# ពិព័រណ៍ពាណិជ្ជកម្ម និង ការតាំងបង្ហាញផលិតផល

## សូមស្វាគមន៍ចំពោះការចូលរួមរបស់លោកអ្នក!

ថ្ងៃអង្គារ៍ ទី១៧ ខែកញ្ញា ឆ្នាំ២០១៧

ទីតាំងនៅសណ្ឋាគារ Radisson Hotel, Chelmsford, MA

ម៉ោង ១២:០០ ថ្ងៃត្រង់ ដល់ម៉ោង ៥:០០ ល្ងាច

- មានការចូលពីក្រុមហ៊ុន និងអង្គការក្នុងស្រុកច្រើនជាង ១០០ ស្ថាប័ណ្ណ
- រីករាយក្នុងការភ្លក់រសជាតិម្ហូបអាហារ
- ចូលរួមដើម្បីឈ្នះផលិតផល Echo Dot ១ រង្វាន់ ក្នុងចំណោម ៤ រង្វាន់
- ចូលរួមក្នុងកម្មវិធីចាប់ឆ្នោតឈ្នះផលិតផល និងការផ្តល់ជូនដោយមិនគិតថ្លៃ
- ការថតរូបប្រើប្រាស់សម្រាប់ការងារ
- កម្មវិធី Photo Booth

យើងសង្ឃឹមថា លោកអ្នកអាចចូលរួមជាមួយយើងខ្ញុំ!

រៀបចំដោយ

circlehealth

www.greaterlowellchamber.org

978-459-8154

#GLCoC

# អត្ថប្រយោជន៍នៃការហាត់ប្រាណ









ការធ្វើលំហាត់ប្រាណបានទៀងទាត់ ពិតជាផ្តល់សារប្រយោជន៍ច្រើនចំពោះសុខភាព មានទាំងសុខភាពរាងកាយផ្លូវចិត្ត និងសម្រស់ ។ អ្នកដែលមិនសូវបញ្ចេញពលកម្ម ឬក៏មិនសូវធ្វើលំហាត់ប្រាណទៀងទាត់ជាទូទៅច្រើនតែជួបបញ្ហាជាច្រើនដូចជា ធាត់លើសទម្ងន់ ឈឺសន្លាក់ អាចកើតមានជំងឺបេះដូង ជំងឺលើសឈាមជំងឺស្ទះសរសៃឈាមបេះដូង ។

ចំពោះសារប្រយោជន៍ដែលបានពីការធ្វើលំហាត់ប្រាណទៀតងទាត់មានដូចជា:

-ធ្វើឱ្យប្រព័ន្ធប្រសាទទាំងអស់ទូទាំងរាងកាយ ដើរស្រួលសម្រាប់ចលនារាងកាយ និងអាចធ្វើឱ្យប្រសើរឡើងនូវពេលវេលាប្រតិកម្មរបស់អ្នក ។

-បង្កើនសមត្ថភាពសួត ដើម្បីធ្វើការមានប្រសិទ្ធភាព ។

-អាចធ្វើឱ្យប្រព័ន្ធសរសៃឈាមបេះដូងដើរបានល្អ ពិសេសបេះដូងអាចច្របាច់ឈាមកាន់តែច្រើនយ៉ាងមានប្រសិទ្ធភាព និងអាចកាត់បន្ថយបន្ទុកការងារលើបេះដូង ។

-ការធ្វើលំហាត់ប្រាណបានទៀងទាត់ពិតជាបានរួមចំណែកក្នុងការជឿជាក់លើខ្លួនឯង និងជួយសម្រួលជាមួយនឹងភាពតានតឹង ស្ត្រេសដែលតែងតែកើតមានលើមនុស្សគ្រប់រូប និងជារៀងរាល់ថ្ងៃ ដែលអាចឈានដល់ការកើតមានជំងឺផ្លូវចិត្តបានយ៉ាងមានប្រសិទ្ធភាព ។

-ពង្រឹងសាច់ដុំ ការលើកដុំដែក នឹងជួយដល់សុខភាពស្បែករបស់អ្នកមានភាពស្រស់ថ្លា រាងកាយមាំមួន ។

-កម្ចាត់ជាតិពុលលើស្បែក។ ការធ្វើលំហាត់ប្រាណជាវិធីល្អបំផុត ដើម្បីបញ្ចេញជាតិពុល និងវិទ្យុសកម្មពីស្បែកដោយពុំបណ្តាលឱ្យស្ទះរន្ធញើសទេ ពិសេសកាត់បន្ថយភាពធាត់ ។

-ការសិក្សាជាច្រើនបានបង្ហាញថា ការធ្វើលំហាត់ប្រាណអាចជួយអ្នកបានយ៉ាងងាយស្រួល ។ សកម្មភាពរាងកាយអាចជួយឱ្យអ្នកមានអារម្មណ៍ងងុយគេង និងគេងបានយ៉ាងស្កប់ស្កល់។ នៅពេលដែលអ្នកបានគេងនោះភ្នែករបស់អ្នកនឹងមិនហើម ហើយមិនខ្មៅទេ ។ ទោះបីជាលោកអ្នកមមាញឹកយ៉ាងណាក៏ដោយ ដើម្បីឱ្យសុខភាពល្អ និងចៀសផុតពីជំងឺផ្សេងៗក្នុង១ថ្ងៃអ្នកគួរតែចំណាយពេលត្រឹម១៥ទៅ២០នាទីដូចជារត់ ជិះកង់ ឬក៏ហែលទឹក ឬបញ្ចេញពលកម្មនានាដែលមិនធ្ងន់ពេក ៕

For your special day...
សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

UMASS LOWELL Inn & Conference Center

**សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ**

ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ផុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។

គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING

KhmerPost USA

### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

Lowell
Lynn
Revere
Providence
Cranston

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

### Khmer Post USA Distribution Locations Include:

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| 2017 PRINTING DATES | 2018 PRINTING DATES |
|---|---|
| July 10 & 24 | January 5 & 19 |
| August 7 & 21 | February 5 & 19 |
| September 11 & 25 | March 5 & 19 |
| October 9 & 23 | April 6 & 20 |
| November 6 & 20 | May 7 & 21 |
| December 4 & 18 | June 8 & 2 |

***Advertising deadlines are 5 business days prior to printing date.***

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10” x 13”) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10” x 6.5”) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5” x 6.5”) | 165 | 940 | 1831 | 3,564 |
| **1/8** (5” x 3.25”) | 90 | 513 | 999 | 1,944 |

### CONTACT INFO

45 Merrimack Street • Suite 218A • Lowell, MA 01852
Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us
www.khmerpost.us

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*

CELEBRATING 10 YEARS